**សម្ភាសន៍ជាមួយ នួន យ៉ុង ភេទប្រុស អាយុ៥៨ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“ប្រធានអនុសេនាតូច-ខ”**

**កើតនៅឃុំវាំងជ័យ ស្រុកសម្រោង ខេត្តកំពង់ចាម**

**សព្វថ្ងៃរស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឌី ខាំបូលី**

**០១:០៧ :២៣**

**៤០ ទំព័រ**

យ៉ុងៈ ចាញ់ល្បិចគេបន្តិចណា៎! ខំអីមិនត្រូវស្លាប់ទេ។

បូលីៈ តា០៥ហ្នឹង ខ្ញីតាទាបាញ់?

យ៉ុងៈ បាទ! គាត់និយាយជាមួយខ្ញុំផ្ទាល់ថាចឹង ថាមិនជឿខ្ញុំចឹង គាត់គេមកគាត់(ស្តាប់ពុំបាន) រួចទៅបានខ្ញុំដឹងថាមិត្តភក្តិ។ សមាហរណកម្ម ខ្ញុំផ្តាច់ខ្លួនហើយក៏ ខ្ញុំចូលទៅព្រះវិហារ ហើយព្រឹត្តិការណ៍ តាម៉ុកហើយប៉ុល ពតឈ្លោះគ្នា ដល់ចឹងក៏គេហៅពួកខ្ញុំថា បេះតែហៅទៅរៀន ខ្ញុំគេហៅទៅរៀន៣ដង តាម៉ុក ហៅទៅរៀន៣ដង។ ខ្ញុំថាទៅ បើដូចសម័យ៣ឆ្នាំនោះងាប់ហើយ អត់ទៅទេ ខ្ញុំដាច់ចិត្តហើយ អត់ទៅទេ!គ្រាន់អត់ទៅរៀន ដល់លើកទី៣ ខ្ញុំដាច់ចិត្តហើយ យើងរៀនទៅបេះតែមកដែរ។ ខ្ញុំទៅរៀន! ពេលចេញមកវិញ មកជំនុំគ្នា ហេតុការអត់ល្អទេ ចុះកាលហ្នឹងតាម៉ុក កាលហ្នឹងដែនការសម្រាប់ខ្ញុំ ហើយសម្លាប់ទាំងអនុសេនាធំទាំងអស់។

បូលីៈ ពេលហ្នឹងតាសារឿន ស្លាប់នៅ?

យ៉ុងៈ ស្លាប់ហើយ!

បូលីៈ ចាប់ហើយណា៎?

យ៉ុងៈ ចាប់តាសារឿន ចាប់អីហ្នឹងហើយអស់។ ដល់ចឹងពួកខ្ញុំនៅក្រោមៗ ខ្ញុំទៅស្រអែមនេះ នាំគ្នាចូលទៅព្រះវិហារទៅ។

បូលីៈ សូមទោស ពូឈ្មោះអីគេពូ?

យ៉ុងៈ ឈ្មោះ នួន យ៉ុង។

បូលីៈ សព្វថ្ងៃ ពូអាយុប៉ុន្មានហើយពូ?

យ៉ុងៈ ខ្ញុំ៥៨ហើយ។

បូលីៈ ស្រុកកំណើតនៅខាងណាទៅ?


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

យ៉ុង: ព្រៃវែងខ្ញុំ ។

បូលី: អ៊ូ! នៅព្រៃវែងចឹង ស្រុកអីគេ?

យ៉ុង: នៅជិតសម្រោង ។

បូលី: បាភ្នំ?

យ៉ុង: បាទ!

បូលី: ភូមិ ឃុំអី?

យ៉ុង: ឃុំរាំងជ័យពីដើម ។

បូលី: ជាមួយហ៊ុម ស៊ីវនតែម្ដង?

យ៉ុង: បងប្អូនដែលហ្នឹងខ្ញុំ បងប្អូនជាមួយហ៊ុម ស៊ីវន ។

បូលី: ចឹង?

យ៉ុង: បាទ!

បូលី: ត្រូវជាយ៉ាងម៉េច?

យ៉ុង: ម៉ែវា ហើយហ្នឹងម៉ែខ្ញុំ ត្រូវជាបងប្អូនជីដូនមួយ ។

បូលី: ជិតតែមួយចឹងនោះ?

យ៉ុង: ជិតដែរ ។

បូលី: ចឹងពូ ហើយហ្នឹងគាត់ត្រូវជាជីទួតមួយ! ព្រោះម្ដាយពូ ហើយនឹងម្ដាយគាត់ត្រូវជាជីដូនមួយគ្នា?

យ៉ុង: ទេ! ដូចជាជីទួតហើយ ។

បូលី: ជីទួតហ៎?

យ៉ុង: បាទ! ព្រោះយាយវា ហើយហ្នឹងយាយខ្ញុំជីដូនមួយ ។

បូលី: ចឹងពូ ហើយនឹងគាត់ត្រូវជាជីលួត?

យ៉ុង: បាទ!

បូលី: តែជីលួត មិនឆ្ងាយប៉ុន្មានទេ ។ តែបើសិនជាពូទៅ គាត់នៅចាំពូទេ?

យ៉ុង: មិនស្គាល់ទេនៅតូចៗ ទាល់តែម៉ែបានស្គាល់ ។

បូលី: ហើយពូចេញពីផ្ទះមកតាំងពីឆ្នាំណាមក ចូលបដិវត្តន៍?

យ៉ុង: ចូលបដិវត្តន៍តាំងពីឆ្នាំ៧០មក ។

បូលី: ៧០?

យ៉ុង: បាទ!

បូលី៖ ចូលដោយស្ម័គ្រចិត្ត ឬក៏គេនាំចូល?

យ៉ុង៖ ស្ម័គ្រចិត្ត! ព្រៃម៉ាគី មួយជំនាន់ព្រៃម៉ាគីហ្នឹង ។

បូលី៖ តបតាមការអំពាវនាវ របស់សម្តេច?

យ៉ុង៖ សម្តេច ។

បូលី៖ សម្តេចឪ?

យ៉ុង៖ បាទ! ក្មេង ។ ខ្ញុំទើបឈប់រៀន បាតុកម្មហ្នឹងក៏ បេះតែដើរគេដើរឯងទៅក្មេងៗ ។

បូលី៖ បាទ! ទីប៉ុន្មានដែរ កាលរៀន?

យ៉ុង៖ ទី៨ ។

បូលី៖ ដល់ចូល ចូលទៅខាងណាវិញ?

យ៉ុង៖ ចូលពួករំដោះ កាលហ្នឹងយើងហៅពួករំដោះ ។

បូលី៖ នៅក្នុងភូមិឃុំយើងទេ?

យ៉ុង៖ បាទ! នៅក្នុងឃុំ ។ មុនដំបូងចូលឈ្លបឃុំ ។ ឈ្លបឃុំបានមួយខែ បានឡើងទៅទ័ពស្រុកល្អោ ។

បូលី៖ ស្រុកបាភ្នំមិនដឹងអេ៎?

យ៉ុង៖ បាទ! នៅទ័ពស្រុក បានមួយឆ្នាំបានឡើងទៅតំបន់២៤ ។

បូលី៖ តំបន់២៤ បាននរណាគេប្រធានតំបន់?

យ៉ុង៖ នេះកាលហ្នឹងឈូក ។

បូលី៖ ឈូកនៅទេ?

យ៉ុង៖ ស្លាប់ហើយកាលហ្នឹង ស្លាប់តាំងពី៧៦នោះ ។

បូលី៖ បន្ទាប់ពីឈ្លបភូមិ គេធ្វើអីទៀតពូ?

យ៉ុង៖ បន្ទាប់ស្រុកនោះ ។

បូលី៖ បន្ទាប់ស្រុក?

យ៉ុង៖ បាទ! មកៗតំបន់២៤ហ្នឹង តាឈូក ។

បូលី៖ ធ្វើអីតំបន់២៤ហ្នឹង?

យ៉ុង៖ ខ្ញុំធ្វើកងទ័ពដែរ ធ្វើកងទ័ពរហូត ។

បូលី៖ កងពលលេខប៉ុន្មាន?

យ៉ុង៖ ក្រោយមកយើង៧៧,៧៨ បង្កើតជាកងពល៨០៥ ។ នេះសុក សារឿននៅ សារឿន អ្នកចម្រៀងនេះ មេសម្តេចហើយពីដើម ។

បូលី៖ អ៊ូ! ចឹងកងពល៨០៥ បង្កើតឆ្នាំ៧៨ទេចឹង?

យ៉ុង៖ បាទ!

បូលី៖ មិនមែនតាំងពី៧៥មកទេ? នរណាគេប្រធានកងពល?

យ៉ុង៖ នៅហ្នឹងបងសារឿនហ្នឹង សុក សារឿនហ្នឹង ។

បូលី៖ សុក សារឿន?

យ៉ុង៖ បាទ! សុក សារឿន ហៅសុក សេនហ្នឹង ។

បូលី៖ មេកងពលណា៎?

យ៉ុង៖ បាទ! ៨០៥ ។

បូលី៖ ចុះអនុកងពល?

យ៉ុង៖ អនុកងពល កាលហ្នឹងពីណា! តាសែន តាអីគេចាប់សម្លាប់ទាំងអស់ហើយ ។

បូលី៖ ហើយកងពល៨០៥នេះបែកចែញជាប៉ុន្មានវរសេនាធំ?

យ៉ុង៖ បាទ! មើលកាលហ្នឹង៧១,៧២,៧៣,៧៤ ។ មាន៤វរសេនាធំ ។

បូលី៖ ៧១?

យ៉ុង៖ ៧០ ។

បូលី៖ ៧០ទៀត? ៧០គត់ ។

យ៉ុង៖ ៧២, ៧៣, ៧៤ ។

បូលី៖ ចុះ៧៥ពូ?

យ៉ុង៖ មាន៧០, ៧១, ៧២, ៧៣, ៧៤ ។

បូលី៖ ៥ចឹងពូ?

យ៉ុង៖ ទេ៥ដឹង! ៧០,៧១,៧២,៧៣,៧៤ ។ ៥!

បូលី៖ ៥វរសេនាធំ ។

យ៉ុង៖ ច្រើនណាស់ចឹង ។

បូលី៖ ហើយពូនៅក្នុងវរសេនាធំមួយណា?

យ៉ុង៖ ខ្ញុំនៅ២៧០ ។

បូលី៖ ២៧០ហ្នឹងតូចទេ?

យ៉ុង៖ វរសេនាធំ ។

បូលី៖ ប៉ុនអានេះវាវរសេនាធំ៧១,៧០,៧២,៧៤ ណាលោកពូ ។ ពូនៅក្នុងអា៧០ហេ៎?

យ៉ុង៖ ២៧០ ។

បូលី៖ បាទ! នៅក្នុងអា៧០ ។ ចុះសម្ដេចហ៊ុនសែនគាត់នៅក្នុងប៉ុន្មានដែរ?

យ៉ុង: ទេ! កាលហ្នឹង តាមនេះគាត់នៅភូមិភាគ ។

បូលី: គាត់មិនមែននៅក្នុងភូមិភាគនេះទេ?

យ៉ុង: បាទ! ប៉ុនតាមគេនិយាយ តាមបងប្អូនខ្ញុំនិយាយ ព្រោះជាមិត្តភក្តិពូខ្ញុំដែរ បើនិយាយពីអតីតវិញ រស់នៅតំបន់២៤ហ្នឹងដែរ តាមដានទៅ ព្រោះពូខ្ញុំនៅ២៤ហ្នឹងដែរ ។

បូលី: តំណែងពូជាអីនៅក្នុងហ្នឹង?

យ៉ុង: កាលហ្នឹងខ្ញុំនៅប្រធាន-ខ ។

បូលី: អគ្គ-ខ?

យ៉ុង: បាទ!

បូលី: ប្រធានអនុសេនាតូចចឹង?

យ៉ុង: បាទ!

បូលី: នៅក្នុងវរសេនាធំលេខ៧០ហើយណ៎?

យ៉ុង: វរៈ៧០ ។

បូលី: ពូមានស្គាល់មេ វរសេនាធំលេខ៧០ទេ?

យ៉ុង: អូយ ។

បូលី: ឈ្មោះ អូយហ៎ ។ ហ្នឹងហើយអូយ! ក្លឹបងសារឿនហ្នឹង! អូយមេ៧០ហើយនែក៎?

យ៉ុង: បាទ!

បូលី: ដល់ពេល៧១?

យ៉ុង: ៧១ ពីដើមបងសារឿនហ្នឹង ។

បូលី: មេកងពលផង មេវរសេនាធំផង?

យ៉ុង: កាលមុនគាត់នៅ កាលមិនទាន់បង្កើតកងពល គាត់មកកាន់ខាងហ្នឹង ។

បូលី: ចឹង!

យ៉ុង: អើ៧២នេះ!

បូលី: ៧២នេះ?

យ៉ុង: សែន ។

បូលី: ៧៣?

យ៉ុង: ៧៣ បងសារឹម បងអ៊ី ។

បូលី: សារឹម! ៧៤?

យ៉ុង: ៧៤ ក្រោយមកដក សែន ហ្នឹងកមកដែរ ប៉ុនអានេះចាប់ ។

បូលីៈ ចាប់ពីណាគេ?

យ៉ុនៈ ចាប់បងសែនហ្នឹង យកទៅសម្លាប់។

បូលីៈ ចុះ៧៤ ចាប់ពីណាគេ?

យ៉ុនៈ អត់មានទេ! អាហ្នឹងបង្កើតក្រោយគេបំផុត។

បូលីៈ អ្ហូ! កើតក្រោយហើយណ៎?

យ៉ុនៈ បាទ! កាលដែលយើង៧៨ហើយហ្នឹង។

បូលីៈ ដកសែន?

យ៉ុនៈ ដងបងសែនហ្នឹងមក។

បូលីៈ មក៧៤?

យ៉ុនៈ បាទ!

បូលីៈ ចឹង៧២ ពីណាគេកាន់វិញចឹង?

យ៉ុនៈ ៧២ដឹងអើ បងលាត ឈ្មោះលាត។

បូលីៈ លាតកាន់វិញនែក៎?

យ៉ុនៈ បាទ!

បូលីៈ លាតនេះបង្កើតក្រោយគេមុនទៀតទេណ៎?

យ៉ុនៈ បាទ! បង្កើតជិតយើងរត់ទៅហើយណ៎។

បូលីៈ រត់ហើយណ៎។

យ៉ុនៈ បាទ! បង្កើតជាកងអន្តរាគមណ៎។

បូលីៈ កងពលនេះកងពលមជ្ឈិម ឬកងពល?

យ៉ុនៈ មជ្ឈិម! ទើបតែកើតយើង៧៧ ទៅ៧៨នេះទេ កងពលហ្នឹង។ គិតទៅមួយភូមិភាគ នៅតែមួយកងពលនេះទេ បានតំបន់២៤ចាស់ហ្នឹង។

បូលីៈ នៅតែទីហ្នឹងទេណ៎?

យ៉ុនៈ នៅតែមួយកងពលហ្នឹងទេ។

បូលីៈ ចុះមុនបង្កើតកងពលហ្នឹង តំបន់២៤មានប៉ុន្មានកងពល?

យ៉ុនៈ វានៅប៉ុន្មានវរសេនាធំនោះ! កាលហ្នឹង មានតែ២វរសេនាធំទេ!

បូលីៈ លេខប៉ុន្មានខ្លះ?

យ៉ុនៈ កាលហ្នឹងវា២៤, ២៥ កាលហ្នឹងគេ-ង កាលហ្នឹង។ ង-២៤ ខ្ញុំហ្នឹង ង-២៥។

បូលីៈ ង-២៥!

យ៉ុង៖ បាទ!

បូលី៖ ចឹងបានន័យថាកងពលនេះ យកពី-២៨, ២៥ទៅ?

យ៉ុង៖ បាទ! ចេះតែប្រុបាច់ចូលគ្នា ដកនោះមក ដកពីនោះមក ដល់យូរៗបាន៣ទៅ៤, ៥ វរសេនាធំហ្នឹងៗ

បូលី៖ ង-២៨! ហើយហ្នឹងង-២៥! ប្រុបាច់បញ្ចូលគ្នាទៅ ហើយរើសមនុស្សបន្ថែមបង្កើតជាកងពលៗ

យ៉ុង៖ ៨០៥ ៗ

បូលី៖ ៨០៥! ហ៊ូ! ខ្ញុំទើបតែឃើញ ខ្ញុំឆ្ងល់កងពល៨០៥ ដូចមិនដែលឮសូរឈ្មោះទេៗ

យ៉ុង៖ ៨០៥ យូរហើយៗ

បូលី៖ យូរហើយ!

យ៉ុង៖ ៨០៥ កាលយើង៧៧ ទៅ៨៧ ដើម៧៨ហ្នឹងៗ

បូលី៖ ដើម៧៨ហ្នឹង?

យ៉ុង៖ បាទ!

បូលី៖ ពេលដែលយើងវាយគ្នាជាមួយយួនខ្លាំង?

យ៉ុង៖ បាទ! ហ្នឹងហើយទើបតែកើតៗ

បូលី៖ ហើយតាសារឿន គាត់មេកងពលហ្នឹង?

យ៉ុង៖ បាទ! កាលហ្នឹងបើមែនទែនគាត់អនុគេទេតាសារឿនហ្នឹង មានទៅពីនិរតីទៅ កាលហ្នឹងមេកងពលឈ្មោះ ផនៗ

បូលី៖ ឈ្មោះ ផន?

យ៉ុង៖ បាទ!

បូលី៖ ផន អនុកងពល មកពីនិរតី?

យ៉ុង៖ បាទ!

បូលី៖ បន្ទាប់ពីតាសារឿន មានទៀតទេ ក្រោមតាសារឿនមួយទៀតមានទេ?

យ៉ុង៖ មានមេៗវរសេនាធំគេហ្នឹងៗ អូយហ្នឹង ក្រោយមកគេ ដកចេញដែរៗ

បូលី៖ គេចាប់ដែរ?

យ៉ុង៖ ដកនៅខាងស្វាយរៀង គេទៅកាន់កងពល៨០៣! ដកផនហ្នឹងមក តាមវរសេនាធំ ២៧០ហ្នឹងផននោះក៏ទៅពីនិរតីដែរៗ

បូលី៖ ផន ប៊ុភណ្ឌ?

យ៉ុង៖ អាមួយ ផន អាមួយ ភណ្ឌ ។

ប៊ូលី៖ ហ៊ូ! ផនផ្សេង ភ័ណ្ឌផ្សេង ។

យ៉ុង៖ ផននៅ៧០ហ្នឹង មកប្រធានវរសេនាធំ៧០ ។

ប៊ូលី៖ បន្ទាប់ពីតា ផុយ ទៅអេ៎?

យ៉ុង៖ បាទ! ប្រធានភូមិក៏គាត់ដឹងដែរ ព្រោះគាត់នៅហ្នឹងដែរ ។

ប៊ូលី៖ ប្រធានភូមិនៅ៨០៥ដែរតូ?

យ៉ុង៖ បាទ! នៅ៨០៥ដែរ ។

ប៊ូលី៖ ហើយ៨០៥ នៅព្រំដែន?

យ៉ុង៖ ព្រំដែន!

ប៊ូលី៖ នៅម្តុំណាព្រំដែន?

យ៉ុង៖ ចាប់ពីកោះរការក្រោមមក ចូលទៅស្វាយរៀង ។

ប៊ូលី៖ នៅក្នុងកំពង់ត្របែក

យ៉ុង៖ ស្រុកពាមជរ កំពង់ត្របែក ។

ប៊ូលី៖ ពាមជរ កំពង់ត្របែក មកទល់ហ្នឹងស្វាយរៀង ។

យ៉ុង៖ ក្រវាត់វៀតណាម ។

ប៊ូលី៖ ក្រវាត់របស់វៀតណាម?

យ៉ុង៖ បាទ!

ប៊ូលី៖ ពេលដែលវៀតណាមវាយចូលមកហ្នឹង យើងស្លាប់ច្រើនទេតូ?

យ៉ុង៖ ទេ! តាមខ្ញុំមើល វាអត់សូវអីដែរ បើស្លាប់ៗ ស្លាប់ច្រើនដែរវៀតណាម! ចូលមកបុក ទំនប់គោកភក់ហ្នឹង គេបាញ់ អើកាលហ្នឹងយើងវាច្បាស់រៀងខ្លួន គេថាគេ យើងថាយើង ។

ប៊ូលី៖ ចុះពេលវៀតណាមវាយបែក យើងរត់ទៅខាងណាទៅតូ?

យ៉ុង៖ រត់មកមួយដួរនេះ មួយដួរពេជ្រនិល ពេជ្រអី ។

ប៊ូលី៖ កំពង់ស្ពឺវិញ?

យ៉ុង៖ បាទ!

ប៊ូលី៖ ចេញពីហ្នឹងមកទៅណាទៀត?

យ៉ុង៖ ខ្ញុំពីហ្នឹងមក នៅតាមព្រំដែន ។

ប៊ូលី៖ ព្រំដែនឯណាវិញ?

យ៉ុង៖ ព្រំដែន មួយដួរប៉ៃលិន ម៉ាឡៃអីហ្នឹង ។

បូលីៈ  អ៊ូ! ពូនៅខាងសំឡូតណា៎?

យ៉ុងៈ  នៅមួយជួរខាងហ្នឹង។ ខ្ញុំដើរមួយជុំវិញ អូនអើយ!

បូលីៈ  ដំបូងបំផុត ពេជ្រនិល រត់មកដំបូងណា៎?

យ៉ុងៈ  បាទ!

បូលីៈ  កាលហ្នឹង នៅពេជ្រនិល ប៉ុន្មានខែ?

យ៉ុងៈ  នៅយូរដែរ! ដល់ចិននៅត្រាំត្រែង១ មកមួយរស់១គេមក គេចិនមក មកមួយជួរម៉ាឡៃ ផ្អាកចិនទៅ បកពីផ្អាកទៅ ម៉ាឡៃ។ ម៉ាឡៃ ដល់នៅ៨៧នេះ ពួកខ្ញុំនៅគាត់ស្រាវជ្រាវ ស្រាវជ្រាវអ្នកព្រៃវែង ចុះទៅខាងវាលហ្នឹង ក៏ដកពួកខ្ញុំមកបានប្រហែលជា២០នាក់ ស្រុកកំណើតនៅនោះ។

បូលីៈ  អ៊ូ! ធ្លាប់នៅ៨៧ដែរហ៎?

យ៉ុងៈ  នៅតា!

បូលីៈ  នៅឆ្នាំ៨៧?

យ៉ុងៈ  បាទ!

បូលីៈ  ពេលដែលរត់មកដល់ពេជ្រនិលភ្លាម យើងឡើងមកភ្នំសិន ឬក៏ធ្វើការនៅក្រោមវិញតែម្តង?

យ៉ុងៈ  ក្រោយមក នៅតាមព្រំដែនចិនទៅក៏ ដល់ចិនកម្លាំងក៏ចេះតែបញ្ជូនទៅក្នុង កំពង់ចាមក្រចេះ។

បូលីៈ  ពូនៅកងពលលេខប៉ុន្មាន នៅពេលដែលមកព្រំដែន?

យ៉ុងៈ  ខ្ញុំ! មុនដំបូងនៅ៥១៩។

បូលីៈ  អ៊ូ! ពូនៅជាមួយតាឌុល សារឿន តាប៉ែន វ៉ៃអីហ្នឹងហ៎ ព្រំ ស៊ូអី?

យ៉ុងៈ  បាទ! មុនដំបូង ខ្ញុំនៅនោះ។

បូលីៈ  ពីណានៅ៥១៩ មុនដំបូងគេបំផុត?

យ៉ុងៈ  មុនដំបូងខ្ញុំនៅជាមួយ តា យន។

បូលីៈ  តា យនហ៎?

យ៉ុងៈ  បាទ!

បូលីៈ  អីគេ យន?

យ៉ុងៈ  ទេ! មិនដឹងស្អីទេ ភ្លេចបាត់ហើយ។

បូលីៈ  តា យន មេកងពល។

យ៉ុងៈ  បាទ!

បូលីៈ  អានុកងពល?

យ៉ុងៈ  ឌុល សាសឿន ។

បូលីៈ  ឌុល សាសឿន កាលហ្នឹង?

យ៉ុងៈ  បាទ!

បូលីៈ  ចុះប៉ែន វយ?

យ៉ុងៈ  ប៉ែន វយ កាលហ្នឹងក្រោមៗដែរ កងពលដែរ ។

បូលីៈ  វរសេនាធំ ឬក៏?

យ៉ុងៈ  កងពលដែរ ប៉ុននៅក្រោមឌុល សារឿន ។

បូលីៈ  ចុះតាព្រំស៊ូ?

យ៉ុងៈ  ព្រំស៊ូ គាត់នៅកងពលដែរ ប៉ុន្តែគាត់នៅក្រោមៗ រងៗ ។

បូលីៈ  រងកងពល?

យ៉ុងៈ  បាទ!

បូលីៈ  ឥលូវ តាព្រំស៊ូ ឥលូវ ធំតូសម ដែរតា?

យ៉ុងៈ  បាទ!

បូលីៈ  ទីប្រឹក្សាក្រសួងការពារជាតិ! ឧត្តមសេនីយ៍ដែរ?

យ៉ុងៈ  ក្មួយគាត់ ញ៉ឹក ប៉ុនណៃ ។

បូលីៈ  បាទ! ក្មួយញ៉ឹក ប៉ុនណៃ ។ ចឹងពូនៅ៥១៩ហេ៎?

យ៉ុងៈ  បាទ! ពីដើម ខ្ញុំនៅហ្នឹង នៅ៥១៩ ។ នៅ៥១៩! នៅ ហុយ ថាំង ។

បូលីៈ  នរណាគេ ហុយ ថាំង?

យ៉ុងៈ  ហុយ ថាំង នៅ៨២ នៅជាមួយប៉ែន វយ ។

បូលីៈ  ប៉ែន វយ គាត់ធ្វើអីលូវ?

យ៉ុងៈ  ប៉ែន វយ គាត់កងពល ៨២នោះ ។

បូលីៈ  កងពល៨២ អាកងពលបង្កើត.?

យ៉ុងៈ  បង្កើតរដ្ឋាភិបាលយើងនោះ ។

បូលីៈ  បង្កើតក្រោយហ្នឹងហេ៎ពូ?

យ៉ុងៈ  បាទ! សមាហរណកម្មហ្នឹង ផ្តាច់ខ្លួនហ្នឹង ។ វ

បូលីៈ  ចឹងពូនៅម៉ាឡៃចឹង?

យ៉ុងៈ  បាទ!

បូលីៈ ចឹងពូចុះមកធ្វើការនៅក្រោម នៅឯណាខ្លះ?

យ៉ុងៈ ៥១៩ នៅមួយជួរភ្នំស្រុក ភ្នំអី។

បូលីៈ មួយជួរភ្នំស្រុក?

យ៉ុងៈ បាទ! ១ជួរស្រុកស្វាយចេក ស្រុកអីហ្នឹង។

បូលីៈ ស្រុកស្វាយចេក។ ថ្មពួកអីធ្លាប់?

យ៉ុងៈ បាទ! ថ្មពួក។

បូលីៈ ហ្នឹងហើយថ្មពួក។ សិរីសោភណ្ឌ?

យ៉ុងៈ បាទ!

បូលីៈ ព្រះនេតព្រះអីមកទេពូ?

យ៉ុងៈ មិនដែលមកដល់ទេ។

បូលីៈ ចុះបន្ទាយអំពិល?

យ៉ុងៈ បន្ទាយអំពិលធ្លាប់ឆ្លងកាត់ ហួសបន្ទាយអំពិលទៀត។

បូលីៈ តាមមាន់ តាក្របីអីធ្លាប់មកដល់ទេ?

យ៉ុងៈ ខាងហ្នឹង ខ្ញុំអត់ដែរទៅទេ។

បូលីៈ ចុះឈូកគគី?

យ៉ុងៈ ឈូកគគី ធ្លាប់ឆ្លងកាត់ដែរ ប៉ុន្តែខ្ញុំនៅអាងក្បាលលាវ ដីថៃនៅជុំគ្នានោះខាង៥១៩។

បូលីៈ ឈូកគគី នរណាគេអ្នកកាន់កាប់ ខាងខ្មែរក្រហម ឬខាងហ៊ុន សុិនប៉ិច?

យ៉ុងៈ កាលហ្នឹង នោះហ៊ុន សុិនប៉ិចនៅនោះម្តងមួយយាម។ ឈូកគគីកាលនោះ អត់មាននរណានៅទេ។

បូលីៈ អត់មានទេណ៎?

យ៉ុងៈ ៩៣ អីហើយបាន ខ្មែរក្រហមមកនៅនោះ។

បូលីៈ ចុះថ្មដូន?

យ៉ុងៈ ថ្មដូន កាលហ្នឹង ហ៊ុន សុិនប៉ិច។

បូលីៈ ហ៊ុន សុិនប៉ិច?

យ៉ុងៈ បាទ! ពួកខ្ញុំនៅក្បែរលាវ។

បូលីៈ ចុះកម្លាំង៥១៩ មាននៅក្បែរបាត់ដំបងទេ?

យ៉ុងៈ មាន! ចុងដាច់។ ចុះទៅខាងទន្លេសាប!

បូលីៈ ទន្លេសាបហ៎?

យ៉ុង៖ បាទ!

បូលី៖ មកម្តុំស្រុកអីគេ?

យ៉ុង៖ ទេ! មួយជួរហ្នឹង ដូចជាស្រុកព្រះនេតព្រះ ស្រុកបាត់ដំបង។

បូលី៖ អាចមកខាងឯកភ្នំអីទេមើលទៅ?

យ៉ុង៖ អត់ទេ! អត់ដល់ហ្នឹងទេ។

បូលី៖ មួយជួរភ្នំលៀស ភ្នំអីចឹងណា?

យ៉ុង៖ អាហ្នឹង មិនដឹងស្រុកអីទេហ្នឹង។

បូលី៖ អាហ្នឹងទៅខាងព្រះនេតព្រះអីវិញចឹង?

យ៉ុង៖ បាទ! នៅក្រោមៗនោះ។

បូលី៖ ព្រះនេត្រព្រះ ស្រុក!

យ៉ុង៖ មួយជួរឪឡឹក មួយជួរអីហ្នឹង។

បូលី៖ ចុះកងពល៤៥០ទៅខាងណាវិញ?

យ៉ុង៖ ៤៥០ ទៅខាងបាត់ដំបងហើយ ពួកហ្នឹងនោះ សុខ ភាពនោះ។

បូលី៖ សុខ ភាព?

យ៉ុង៖ ហ្នឹងហើយសុខ ភាព?

បូលី៖ សុខ ភាពទៅខាងបាត់ដំបងហើយនេះ?

យ៉ុង៖ បាទ!

បូលី៖ ហើយ កងពលខាងតានី កន,៣២០អី ដែរស្គាល់ខាងហ្នឹងទេពូ?

យ៉ុង៖ ខ្ញុំអត់សូវស្គាល់ទេខាងហ្នឹង។

បូលី៖ ស្គាល់តែរបស់យើង៥១៩?

យ៉ុង៖ បាទ! ស្គាល់តែរបស់យើង៥១៩។

បូលី៖ ៥១៩ យើងប្រតិបត្តិតាមព្រំដែនពី ចន្លោះម៉ាឡៃទៅ ឈូកគគីណ៎អឺ?

យ៉ុង៖ បាទ!

បូលី៖ ចឹងសុទ្ធតែ៥១៩ទាំងអស់ហើយណ៎?

យ៉ុង៖ បាទ! ជួបត្រឹមាន់ ត្រឹអីនេះ សុទ្ធតែ៥១៩ហើយ។

បូលី៖ ចឹងពូនៅមួយជួរម៉ាឡៃ រហូតដល់ ឈូកគគី ថ្មពួក ស្វាយចេក អូរជ្រៅ ខាង៥១៩?

យ៉ុង៖ ខាងនេះ៤៥០! ប៉ែកខាងត្បូង។

បូលី៖ ប៉ែកខាង៤៥០?

យ៉ុង៖ បាទ!

បូលី៖ ចឹងពីអូរជ្រៅ មកខាងត្បូង ៤៥០ ។

យ៉ុង៖ បាទ!

បូលី៖ ពីអូរជ្រៅមកខាងជើង៥១៩?

យ៉ុង៖ បាទ!

បូលី៖ បាទ! យល់ៗ ហើយម៉េចទៀតទៅពូ បានពូចេញពី៥១៩មក?

យ៉ុង៖ ឆ្នាំ៨៧ហ្នឹង បានតាម៉ុក អ្នកស្រាវជ្រាវ អ្នកព្រៃវែង ។

បូលី៖ ម៉េចចឹង បានរកអ្នកព្រៃវែង?

យ៉ុង៖ គេឲ្យចុះទៅធ្វើការហ្នឹង ។

បូលី៖ ឲ្យចុះទៅធ្វើការនៅព្រៃវែងនោះ?

យ៉ុង៖ បាទ!

បូលី៖ ម៉េចទៅ បើគាត់ស្រាវជ្រាវឃើញ យ៉ាងម៉េចទៅ?

យ៉ុង៖ មានខ្លះ នៅខាងព្រៃវែង ដល់អីចឹងទៅ មានអីចាស់មួយនោះ គាត់ស្លាប់ហើយ បានគាត់មក នៅជាមួយតាម៉ុក តាម៉ុក គាត់ស្រាវជ្រាវទៅគាត់នៅព្រៃវែងដែរ ។

បូលី៖ គាត់យកពូទៅណាទៅចឹង?

យ៉ុង៖ ដល់ចឹង យកខ្ញុំមកនៅហ្នឹងចឹងទៅ ព្រោះតាម៉ុក គាត់កាន់មួយហ្នឹង ។

បូលី៖ ចឹងក៏ដកពូមកនៅ១០០៣នេះមក?

យ៉ុង៖ ដល់ចឹងពួកខ្ញុំ ក៏ចុះទៅមួយដួរហ្នឹង១០០៣ ។

បូលី៖ ចឹងក៏ដក់ពូមក១០០៣នេះមក ។

យ៉ុង៖ ដល់ចឹងពួកខ្ញុំក៏ចុះមកដល់ កំពង់ចាម ខេត្តកំពង់ចាម មួយដួរត្បូងឃ្មុំ ត្បូងអី ។

បូលី៖ ពូនៅ១០០៣ហ៎?

យ៉ុង៖ បាទ!

បូលី៖ ១០០៣ ឆ្នាំ៨៧?

យ៉ុង៖ បាទ!

បូលី៖ ៨៧ ចុះមកខាងកំពង់ចាមនេះ ។

យ៉ុង៖ បាទ!

បូលី៖ ហើយក្រែងគេចង់ឲ្យពូមកព្រៃវែង អីកាលហ្នឹង?

យ៉ុង៖ ព្រៃវែងអី បើយើងមកអត់រួច ។

បូលី៖ បានទៅកំពង់ចាមសិន?

យ៉ុង៖ បាទ! បានត្រឹមកំពង់ចាម ។

បូលី៖ ៨៧ បែបសភាពការណ៍យ៉ាប់ៗ បើកាលពី ក្រោម៨៥ចុះ ពេលវៀតណាម យួនវាយតាមព្រំដែននេះ អាហ្នឹងអាចចូលដល់ ព្រៃវែងទេ?

យ៉ុង៖ បាទ!

បូលី៖ អាចចូលដល់ស្វាយរៀងទៀតអត់?

យ៉ុង៖ ទៅដល់ត្រឹមនេះទេអូន ដល់ត្រឹមក្រចែ ក្រចៅ ។

បូលី៖ ក្រចៅ! ស្រុកអីដែរពូ?

យ៉ុង៖ ស្រុកចែក្រចៅហើយនោះ ស្រុកកំចាយមារ ។

បូលី៖ ហ៊ូៗ! កំចាយមារ ក្បែរកញ្ច្រៀចដែរចឹង?

យ៉ុង៖ បាទ!

បូលី៖ កៀកស្វាយរៀងហើយ?

យ៉ុង៖ បាទ! ស្វាយរៀងក៏មានលូកទៅដែរកាលហ្នឹង ។

បូលី៖ កៀកនេះហើយជាប់រមាសហែក! មកដល់ចឹងដែរ?

យ៉ុង៖ បាទ!

បូលី៖ នៅកំពង់ចាមយើង មានទីតាំងមន្ទីរពេទ្យ ឬទីតាំងផ្ទុកគ្រាប់របស់ខ្មែរក្រហមទេ?

យ៉ុង៖ គ្មានទេ! គ្រាន់តែមានពេទ្យថ្នាក់តិចតួចនៅក្នុងព្រៃណា ។ គ្រាន់ថាគ្រាប់វាសម្បូរ ហូរហៀរគ្មានទេ ។

បូលី៖ ពេលហ្នឹងយើងម្ចាស់ការខ្លួនឯង ឬយ៉ាងម៉េច?

យ៉ុង៖ អត់ទេ! យើងគ្រាន់តែទៅកសាងជាស្នូល ជាបណ្ដាញអីចឹងណា ។

បូលី៖ ប៉ុន្តែ កាហ្វបចុក យើងម្ចាស់ការខ្លួនឯង?

យ៉ុង៖ លុយ ឧបត្ថម្ភឲ្យទៅពីលើខ្លួន ។

បូលី៖ ឲ្យលុយទៅហ៎?

យ៉ុង៖ បាទ!

បូលី៖ ប៉ុន្មាន?

យ៉ុង៖ បើយើងទៅយូរ គឺឲ្យច្រើន ។

បូលី៖ គេបើកជាប្រាក់ខែ ឬក៏យ៉ាងម៉េច?

យ៉ុង៖ អត់មានប្រាក់ខែឲ្យ គ្រាន់តែលុយសម្រាប់ទិញអង្ករ ម្ហូបអីចឹង ។

បូលីៈ ប៉ុន្តែមិនមែនប្រាក់ខែទេ?

យ៉ុងៈ អត់មានទេ ។ គ្រាន់តែប្រាក់ជីវភាពសម្រាប់ហូប ។

បូលីៈ ពេលយើងចុះមកអីចឹង១ឆ្នាំ ប៉ុន្មានបានគេឲ្យទៅវិញម្តង?

យ៉ុងៈ ទេ! ខ្ញុំទៅឆ្នាំដំបូង៣ឆ្នាំ ។

បូលីៈ ចុះមក៣ឆ្នាំ?

យ៉ុងៈ បាទ! ៣ឆ្នាំ បានឡើងមកជួប ប្រពន្ធកូនម្តង យូរៗដែរ ។

បូលីៈ ពូការឆ្នាំ ប៉ុន្មាន?

យ៉ុងៈ ឆ្នាំ៧៩ ។

បូលីៈ ការនៅឯណា?

យ៉ុងៈ នៅស្រុកនោះ ។

បូលីៈ ស្រុកព្រៃវែង?

យ៉ុងៈ បាទ!

បូលីៈ ចឹងបានន័យថាម៉េច?

យ៉ុងៈ ខ្ញុំ៧៨!

បូលីៈ មុនបែកហ៎?

យ៉ុងៈ បាទ!

បូលីៈ ដល់ពេលនោះ យើងរត់ទៅជាមួយពូ ជាមួយមីងដែរ ឬក៏បែកគ្នាកាលហ្នឹង?

យ៉ុងៈ ខ្ញុំជួបគ្នារហូត ។

បូលីៈ ជួបគ្នារហូត ។ ហើយមកនៅ៥១៩ នៅជាមួយមីងដែរ?

យ៉ុងៈ នៅជាមួយគ្នាដែរ ។

បូលីៈ ដល់ពេលតាម៉ុក រើសមក១០០៣មក?

យ៉ុងៈ មកជុំគ្នាដដែរ ។

បូលីៈ ពេលដែលមកនៅ១០០៣ ពូបានកូនប៉ុន្មានហើយ?

យ៉ុងៈ ខ្ញុំកូន២ ។

បូលីៈ កូន២ហើយនែក៎?

យ៉ុងៈ បាទ!

បូលីៈ ចឹងមីងនៅនេះមានកូន ឬនៅ?

យ៉ុងៈ នៅ ។

បូលី៖ ៥១៩ណា៎?

យ៉ុង៖ មានហើយ មានគុនហើយដែរ ។

បូលី៖ កូន២ហើយ ។ ដល់តែមីងមានកូនចឹង គេតម្រូវឲ្យធ្វើការទេ?

យ៉ុង៖ អត់មានធ្វើអីទេ កាលជំនាន់នោះណា៎ ។ យើងនៅតែមើលកូន មើលចៅទៅ ហើយរបស់របប អីគេ រដ្ឋគេឧបត្ថម្ភ យើងថារដ្ឋចុះ ។

បូលី៖ អត់មជញ្ជូនគាប់អីគេទេណា៎?

យ៉ុង៖ អត់ទេ! អានោះមានកងគេ ផ្សេងទៀត កងជញ្ជូនអី ។

បូលី៖ ចឹង៨៧ ពូចុះមកកំពង់ចាម?

យ៉ុង៖ បាទ!

បូលី៖ ពេលណាបានទៅវិញ?

យ៉ុង៖ ខ្ញុំទៅជំបូង ២ ទៅ៣ឆ្នាំបានមក ។ បានឡើងមកវិញ!

បូលី៖ ចុង៨៩ តាម៉ុក គាត់ចាប់ផ្ដើមយកអន្លង់វែងហើយណា?

យ៉ុង៖ បាទ!

បូលី៖ ឆ្នាំ៩០ បញ្ជូនប្រជាជន មីងចុះមកក្រោមហើយ?

យ៉ុង៖ បាទ!

បូលី៖ ពេលហ្នឹងពូនៅឯណាហើយ?

យ៉ុង៖ បែកអន្លង់វែង ខ្ញុំឡើងអីក្នុង ឆ្នាំបែកអន្លង់វែងនេះ ។

បូលី៖ ពូឡើងមុនបែក ឬក្រោយបែក?

យ៉ុង៖ បែកហើយ បានមក ។

បូលី៖ ក្រោយ?

យ៉ុង៖ បាទ! ក្រោយបែក ។ បែកកអន្លង់វែងហើយ អីហើយបានមក ។

បូលី៖ បានវាយជាមួយគេទេ?

យ៉ុង៖ អត់ទេ! ខ្ញុំនៅតែក្នុងទេ ។

បូលី៖ នៅតែក្នុងទេ?

យ៉ុង៖ បាទ!

បូលី៖ ដល់តែពេលឡើងមក ឡើងទៅលើភ្នំ ឬក៏មកអន្លង់វែងតែម្ដង?

យ៉ុង៖ នៅលើភ្នំ អត់ទាន់មានមកអន្លង់វែង ។

បូលី៖ ទៅលើភ្នំសិនហ៎?

យ៉ុង៖ បាទ!

បូលី៖ ១០០៣ហ៎ពូ?

យ៉ុង៖ បាទ! នេះទីនេះទៅ១០០៣តិចៗ ជាំស្វា!

បូលី៖ ជាំស្វា?

យ៉ុង៖ បាទ!

បូលី៖ ជាំស្វានៅក្បែរឈូករុនចឹង?

យ៉ុង៖ បាទ! ទៅក្រោយឈូករុននោះៗ

បូលី៖ អានេះព្រះប្រឡាយ! អានេះអូរស្វាយ! មកនេះក្បាលទន្សោង អានេះព្រំប្រទល់ត្រពាំង ប្រាសាទនៅអន្លង់វែងណាពូ?

យ៉ុង៖ បាទ!

បូលី៖ ខាងនេះត្រពាំងអន្លង់វែង ចឹងពូនៅជាំស្វានេះ?

យ៉ុង៖ បាទ!

បូលី៖ មីននៅហ្នឹងដែរ?

យ៉ុង៖ បាទ! គាត់នៅតែក្រោយ ខ្ញុំនៅតែក្នុងៗ

បូលី៖ មីងនៅឯក្រោយ ពូនៅឯក្នុង?

យ៉ុង៖ បាទ!

បូលី៖ ដល់ពេលមីង ចុះមក ចុះមកតាមណា តាមឈូករុន ឬតាម?

យ៉ុង៖ តាមឈូករុនៗ

បូលី៖ បាទ!

យ៉ុង៖ ឆ្លងអូរ៥០ៗ

បូលី៖ ឆ្លងអូរ៥០នេះ?

យ៉ុង៖ បាទ!

បូលី៖ អូរ៥០នេះវាមាន អូរមួយចុះទៅខាងក្នុងដីខ្មែរយើង?

យ៉ុង៖ ហ្នឹងហើយៗ អូរ៥០ អូរអីមួយទៀតហើយ! អូរក្រញូ៉ងៗ

បូលី៖ អូរក្រញូ៉ង?

យ៉ុង៖ បាទ! ចុះពីស្មោរាប មកប៉ះអូរក្រញូ៉ង នៅក្រោយអូរក្រញូ៉ងហ្នឹងៗ

បូលី៖ ចុះមានអូរបេង អូររំដួលអីពូ?

យ៉ុង៖ អូរបេង! ស្រុកថៃ?

បូលីៈ ស្រុកខ្មែរយើងណា?

យ៉ុងៈ មាន! អូរបេង ។ អូរបេងត្រពាំងប្រាសាទ អូររំដួលកើត ។

បូលីៈ នៅក្នុងព្រះប្រឡាយដែរ?

យ៉ុងៈ បាទ!

បូលីៈ ដល់ពេលចុះមកពូមកនៅឯណា ដំបូង?

យ៉ុងៈ ខ្ញុំនៅក្រោមនោះពីមុន នៅដីរាប នៅក្រោយៈនោះ ។

បូលីៈ ភូមិ ឃុំអីគេហៅ?

យ៉ុងៈ ឃុមទួលចាររាល់ថ្ងៃ ឃុំហ្នឹង ។

បូលីៈ ចឹងពេលចុះមកភ្លាមពូមកនៅទំនប់ដាច់តែម្តង?

យ៉ុងៈ ចុះមកនៅ ប៉ុននៅដល់ខែ វស្សាវាដីជាំពេក វាឡើងមកនៅឯនេះ ។

បូលីៈ ហើយក៏មកនៅនេះរហូតមក?

យ៉ុងៈ ទេ! ដល់៩៨ ។ ៩៨ហ្នឹងទាហានរដ្ឋាភិបាល វាវាយហ្នឹង រត់ទៅនោះ ស្វាយលិចនោះ ។

បូលីៈ អូរចឹងមុនដំបូងយើងនៅទំនប់ដាច់ឯនោះ ពូណ៎?

យ៉ុងៈ បាទ!

បូលីៈ អូរស្វាយនៅនេះ ហើយទាហានរដ្ឋាភិបាលដេញពីនោះមកវិញ?

យ៉ុងៈ បាទ!

បូលីៈ ដេញមកយើងមកនៅអូរស្វាយនេះ ហើយ៩៨ មកនៅអូរស្វាយ?

យ៉ុងៈ បាទ!

បូលីៈ ពេលណា បានត្រលប់មកទំនប់ដាច់វិញ?

យ៉ុងៈ ឆ្នាំ៩៨ ។ ឆ្នាំ៩៨ហ្នឹង ដល់ពួកហ្នឹង ដាច់ខ្លួនក៏នាំគ្នាមកនៅហ្នឹងវិញទៅ ។

បូលីៈ ខ្ញុំចង់សុំសួរកន្លែងរឿងផ្តាច់ខ្លួនហ្នឹងតិច! មុនពេលដែលយើងមានផែនការផ្តាច់ខ្លួន គឺយើងមានការសម្លាប់តា សុន សេន ហើយនឹងមានជម្លោះនឹងតាប៉ុល ពតសិន មិនចឹងពូ?

យ៉ុងៈ បាទ!

បូលីៈ បានៗមានផែនការ ផ្តាច់ខ្លួនតាមក្រោយ ។ ពេលហ្នឹងពូ មានបានដឹងទេថា រឿងអីបានជាប្រែប្រួលតាមក្រោយ ។ ពេលហ្នឹងពូ មានបានដឹងទេថារឿងអីបានជាសុន សេនស្លាប់កាលហ្នឹង?

យ៉ុងៈ ខ្ញុំក្តាប់ពុំបានដែរ ។

បូលីៈ ដឹងអត់ច្បាស់ ។ បើតាមគេត្មុ គេថាម៉េច? និយាយតៗគ្នា?

យ៉ុងៈ តាមគេត្មុ ខ្ញុំដូចជាមិនច្បាស់ដែរ ។ ហ្នឹងអត់ហានថាផង!

បូលី៖ ចុះមួយទៀតទាក់ទង ទៅហ្នឹងជម្លោះ រវាងតាម៉ុក និងតាប៉ុល ពត បន្ទាប់ពីតាសុន សេន ស្លាប់ទៅហើយណាពូ អាហ្នឹងវាយ៉ាងម៉េចវិញពូ? ម៉េចបានគាត់២ហ្នឹង ទៅជាឈ្លោះគ្នាវិញ?

យ៉ុង៖ ខ្ញុំក្តាប់ពុំបានដែរ ការងាររខាងលើ ខ្ញុំអត់ហានថា ។

បូលី៖ ពេលពូមកនៅ១០០៣ ពូមកនៅកងពលលេខប៉ុន្មាន?

យ៉ុង៖ កងពល៨០១!

បូលី៖ របស់តាសារឿនហេ៎?

យ៉ុង៖ បាទ!

បូលី៖ ចុះតាភីម គាត់ធ្វើអីកាលហ្នឹង?

យ៉ុង៖ ភីម ភូមិភាគបូព៌ា សោ ភីមហ្នឹងណា៎ ។ សូ សុវណ្ណហៅសោ ភីម ណា ប្រធានភូមិភាគបូព៌ា ។

បូលី៖ ទេ! សោ ភីមហ្នឹង ស្លាប់យូរហើយណា៎!

យ៉ុង៖ ស្លាប់យូរហើយ ។

បូលី៖ ប៉ុនភីមដែលនៅនេះ ។ អ៊ូស៊ីមហេ៎? តាស៊ីម! តា ស៊ីម គាត់៨០១ដែរ?

យ៉ុង៖ ៨០១ គាត់ ។

បូលី៖ គាត់តំណែងជាអីគាត់ ។

យ៉ុង៖ កាលហ្នឹងវរសេនាធំ! តាស៊ីម ។

បូលី៖ លេខប៉ុន្មាន?

យ៉ុង៖ ខ្ញុំក្តាប់មិនបាន ទើបតែចូលមកឆ្នាំ៨៧ហ្នឹង!

បូលី៖ ក្រោយគេទេណា៎?

យ៉ុង៖ បាទ! ចូលមក៨០១ ។

បូលី៖ ពេលដែលចុហមកក្នុងនេះ ៨០១នៅឡើយទេ ។

យ៉ុង៖ បាទ! ពេលហ្នឹង តាសារឿន ដឹកនាំកម្លាំង វាយជាមួយតាម៉ុក កាលហ្នឹង ពូទៅវាយជាមួយគេដែលទេកាលហ្នឹង?

បូលី៖ វាយណា វាយតាសុន សេនហ្នឹងហេ៎?

យ៉ុង៖ អត់ទេ! វាយជាមួយតាម៉ុក ហ្នឹងណា៎ ។ អត់! ខ្ញុំទៅវាយជាមួយតាម៉ុក អត់វាយ ។

បូលី៖ ពូទៅវាយជាមួយនរណាគេកាលហ្នឹង?

យ៉ុង៖ ខ្ញុំនៅក្រោយនេះ ។

បូលីៈ ក្រោយវិញ ។

យ៉ុងៈ បាទ!

បូលីៈ ម៉េចបានយើងអត់ទៅចូលរួមជាមួយហ្នឹងគេកាលហ្នឹង?

យ៉ុងៈ ផ្ទៃក្នុងឈ្លោះគ្នា ខ្ញុំទៅដែរ ប៉ុន្តែអត់បានវាយ អត់បានអីទេកាលហ្នឹង ។ គេវាយមុនហើយ បានខ្ញុំទៅក្រោយ ទៅក្រោយ ។

បូលីៈ ទៅក្រោយជួយគេអត់ទាន់?

យ៉ុងៈ បាទ! ទៅក្រោយ ទៅសែងតាប៉ុល ពតមកវិញហ្នឹង ។

បូលីៈ ហ៎ូពូអ្នកសែងដែរ?

យ៉ុងៈ ខ្ញុំអ្នកសែងផ្ទាល់ ។

បូលីៈ ចឹងហ៎?

យ៉ុងៈ បាទ!

បូលីៈ ពូអាចនិយាយបន្តិចបានទេ ធ្វើម៉េចបានរកតាប៉ុល ពតឃើញ?

យ៉ុងៈ កាលហ្នឹងវាចេះ ចាំមើល កាលនោះខ្ញុំទៅ គេចប់វាយគ្នាហើយណា តាប៉ុល ពតថាឈប់វាយគ្នាទៅយើងដោះស្រាយគ្នា ដល់ចឹង ខ្ញុំក៏សែងគាត់មកទៅ ។ សែងៗដល់កន្លែងលាក់កន្លែងលាក់ គិតទៅអ្នកសែងទាំងអស់មក គាត់ហៅខ្ញុំនិយាយថាឥលូវមិត្តឯង ទៅនៅជាមួយខ្ញុំទៅ ហើយខ្ញុំឆ្លើយ ដូចអត់ឆ្លើយជាមួយគាត់ចឹង ។ ដល់ចឹងតាសារឿន ០៥ហ្នឹង គាត់មកថាអឹមិនបាច់ឲ្យនៅទៅធ្វើការនៅក្រោម ខ្ញុំក៏ចុះមកទៅចុះមកផ្ទះ ដល់មកទៅក៏ពួកតាម៉ុក ពួកអីមកចុះមកខ្ញុំ មកដល់ៗភ្នំ ដកកាំភ្លើង ដកអីអស់ តេអ្ហូ តេអី ខ្ញុំចុះមកផ្ទះមក ។

បូលីៈ ចឹងពេលដែល តាប៉ុល ពត គាត់រត់ តាម៉ុកវាយហ្នឹងណា តាប៉ុល ពត គាត់មិននៅក្បាលទន្លេរាងត្រូវទេពូ?

យ៉ុងៈ ត្រូវហើយ!

បូលីៈ ហើយពេលហ្នឹង តាសារឿន តា០៦អីមិនវាយជាមួយតាម៉ុក ពេលដែលវាយមកមិនបាក់ទ័ពព្រោះអីកម្លាំងតាម៉ុកច្រើនជាងនោះ មិនតាប៉ុល ពតរត់មក ។ ពេលហ្នឹងពូរត់ជាមួតាប៉ុល ពតទេ?

យ៉ុងៈ រត់! ខ្ញុំអ្នកសែងគាត់ណា ។

បូលីៈ ពូអ្នកសែងគាត់រត់មកណា?

យ៉ុងៈ បាទ!

បូលីៈ រត់មកខាងណាវិញ?

យ៉ុង៖ មកដល់អូរស្វាយនេះ ។

បូលី៖ អូរស្វាយនេះ?

យ៉ុង៖ បាទ!

បូលី៖ ហើយទៅលាក់ខ្លួននៅកន្លែងណាទៅ?

យ៉ុង៖ ដល់ពេលក្រោយមកចុះមកក្រោម មានទៅលាក់ទៅណាវិញ ។

បូលី៖ ប៉ុន្តែ ពេលពួសែងតាប៉ុល ពតមកលាក់ខ្លួននៅម្តុំណា?

យ៉ុង៖ អត់ទាន់យកលាក់ទេ នៅទីហ្នឹង ។ នៅក្បាលទន្លេវាងទាល់តែបង០៥នោះមក! ដល់ខ្ញុំចុះមកក្រោមគាត់យកទៅលាក់ទៀតទៅ ខ្ញុំមិនដឹងលាក់ត្រង់ណា ។

បូលី៖ អូ៎! យល់ហើយ ។ មកដល់អូរស្វាយគេហៅ ម្តុំអីដែលពួសែងតាប៉ុល ពតមក?

យ៉ុង៖ គេហៅក្បាលអូរស្វាយតែម្តងទីហ្នឹង ។

បូលី៖ អូរស្វាយតែម្តង?

យ៉ុង៖ បាទ! ក្បាលអូរស្វាយ តែម្តងនេះ ។

បូលី៖ មាន២កន្លែង កន្លែងនេះមួយ កន្លែងនេះ២ អូរស្វាយ! អានេះអូរស្វាយ ខ្សែពណ៌ខៀវពួ ។ អាហ្នឹងអូរណោ៎ពួណា អូរវាហូរចាក់មកចឹងមកនៅនេះ អូរក្បាលវា ក្បាលវានៅម្តុំនេះ បើយើងឡើងមកទីនេះអូរត្រាវ អូរ៤០៣ហើយយើង ។ ចាក់នៅលើដីថៃណាស់ ចេញពីក្បាលទន្លេវាងមកនេះវាឆ្ងាយដែរណា ។

យ៉ុង៖ ឆ្ងាយ!

បូលី៖ វាស៊ីប៉ុន្មានគីឡូ? ពួសែងគាត់គាត់ប៉ុន្មានយប់ ប៉ុន្មានថ្ងៃ?

យ៉ុង៖ មួយយប់ ទល់ភ្លឺ ។

បូលី៖ មួយយប់ទល់ភ្លឺ! សែងហ្នឹងអី?

យ៉ុង៖ សែងស្នែងយើងហ្នឹង ។

បូលី៖ ដាក់អង្រឹង?

យ៉ុង៖ បាទ

បូលី៖ ប៉ុន្មាននាក់ប្តូរ?

យ៉ុង៖ ហ៊ឹម! មានច្រើនណាស់ ។

បូលី៖ ប្តូរផ្លាស់ៗ! ពេលរត់ បាក់ទ័ពមកហ្នឹង ទាំងតាសារឿន ទាំងអីមកហ្នឹង កម្លាំងខាងប៉ុល ពតទាំងអស់នេះប្រហែលប៉ុន្មាន?

យ៉ុង៖ កាលជំនាន់ហ្នឹង! បែកខាងហ្នឹងហេ៎! បែកខាងតាប៉ុល ពត នេះកម្លាំងច្រើនដែរ តែគាត់អត់ឲ្យវាយ!

បូលី៖ គាត់អត់ឲ្យវាយ ឬក៏គាត់ចាញ់?

យ៉ុង៖ ទេ! គាត់អត់ឲ្យវាយ ។

បូលី៖ ប៉ុនវាយគ្នា ៣ទៅ៤ថ្ងៃរួចហើយ?

យ៉ុង៖ បាទ!

បូលី៖ គាត់ថាម៉េចបានជាគាត់អត់ឲ្យវាយ?

យ៉ុង៖ ដឹងម៉េចផង គាត់បញ្ជាអត់ឲ្យវាយ ។

បូលី៖ គាត់យល់ឃើញថាចង់ចរចា ឬក៏យ៉ាងម៉េច?

យ៉ុង៖ ថាផ្សះផ្សាគ្នាទៅ កុំវាយគាត់និយាយ ។

បូលី៖ គាត់និយាយតែចឹងម្ដង?

យ៉ុង៖ បាទ!

បូលី៖ ហើយតាសារឿន គាត់ព្រមទេចឹង?

យ៉ុង៖ គាត់ព្រម! ព្រមបានរត់ទៅចាប់ ដល់ចឹងទៅក៏គាត់លាក់មក ហើយក៏យកគាត់មកលាក់ទៅ ។ ដល់ចឹងទៅបង០៦ អីហ្នឹង ក្រុមតាម៉ុកហៅមកប្រជុំ មកអីជន្ទងគាត់នោះ ។ ជន្ទងបង០៦!

បូលី៖ បាទ! តា០៥ហ្នឹងហេ៎?

យ៉ុង៖ បាទ! ឲ្យទាក់ទងទៅអូរហៅ កម្លាំងគេទៅយកទៅ! ប្រពន្ធគាត់អីហ្នឹង ។

បូលី៖ ចឹងតា០៥ ហើយនឹងតា០៦ ហៅគ្នាមកប្រជុំ?

យ៉ុង៖ ហៅប្រជុំអីហៅមក ពេលដេលចាញ់គ្នាមកហើយណ៎ ។

បូលី៖ ហើយបកក្រោមមកនេះ ជួបគ្នា?

យ៉ុង៖ បាទ! ហៅមកជាមួយមកតា តាមិនធ្វើអីទេ ហៅមកក៏មកទៅ ។

បូលី៖ អូ៎! តាម៉ុកហៅពួកគាត់ទៅវិញ?

យ៉ុង៖ បាទ!

បូលី៖ តាម៉ុក ហៅតា០៥,០៦មក?

យ៉ុង៖ បាទ! បង០៦ គាត់អត់រត់ចេញទេ គាត់នៅហ្នឹង ។ គាត់រត់តែតា០៥ទេ ។

បូលី៖ រត់ពីណាវិញ?

យ៉ុង៖ រត់ពីក្បាលទន្លេរាងហ្នឹងមក បង០៦ចុះទៅផ្ទះគាត់ទៅ! បង០៥ គាត់ចេះតែមកៗទៅ មកកើតនោះទៅ ។

បូលី៖ ចឹងបានគេចេះតែចាប់តា០៦មុន?

យ៉ុង៖ បាទ!

បូលី៖ ហើយបានចាប់តា០៥តាមក្រោយ?

យ៉ុង៖ បាទ!

បូលី៖ ០៦ អត់រត់ទេណ៎? រត់តែ០៥?

យ៉ុង៖ បាទ!

បូលី៖ ០៦ គាត់ដូចជាមានផ្ទះមួយនៅអន្លង់វែង?

យ៉ុង៖ ផ្ទះមួយនៅអន្លង់វែង!

បូលី៖ ឬក៏ផ្ទះគាត់តែម្តង គាត់ដែរមានផ្ទះនៅត្រពាំងប្រាសាទទេ?

យ៉ុង៖ អត់មានទេ បង០៦ ។

បូលី៖ គាត់មានផ្ទះនៅអន្លង់វែង កូនអីនៅអន្លង់វែងទាំងអស់?

យ៉ុង៖ នៅនេះមួយ!

បូលី៖ បងសាមុតហ៎?

យ៉ុង៖ ហ្នឹងហើយប្តីប្រពន្ធគេ ។

បូលី៖ ប្តីប្រពន្ធគេ! ខ្ញុំទៅជួបតា ឃើញចៅតា០៥,០៦ ប្អូន ទៅប្រាំនាក់សុទ្ធតែស្រីៗ ។

យ៉ុង៖ កូនវាធំដែរហើយ ។

បូលី៖ ដល់ពេលហើយ ពូសែងតា ប៉ុល ពត មកហ្នឹងហើយ ដល់ពេលមកមានតាណាខ្លះអ្នកធំៗ? មានតាខៀវសំផនអីទេ?

យ៉ុង៖ តាមដែលខ្ញុំជួប តាប៉ុល ពត មានតែតាខៀវ សំផនទេនៅជាប់រហូតតែម្តង ក្រៅពីហ្នឹងបែក អស់ហើយ ។

បូលី៖ ចុះទេព ខណាល់?

យ៉ុង៖ ទេព ខណាល់អត់ជួបទេ។ ជួបផ្ទាល់គឺមានតែ តាខៀវ សំផនទេ។

បូលី៖ តាមនួន ជា?

យ៉ុង៖ នួន ជាក៏អត់ជាប់ដែរ ។

បូលី៖ ចាន់ យូរ៉ាន់?

យ៉ុង៖ ក៏អត់ដែរ ។

បូលី៖ អត់ឃើញទេ!

យ៉ុង៖ គាត់ដើរមួយបែកផ្សេង ចាំមើល ដល់ពេលខ្ញុំសែងណា៎ ។ អ្នកជួបគាំនោះមានតែ កូនក្មួយៗ គាត់ ប្រពន្ធគាត់ ហើយអឹមខៀវ សំផនតែប៉ុណ្ណឹងទេ ។

បូលី៖ ប្រពន្ធខៀវសំ ផន?

យ៉ុង៖ ប្រពន្ធខៀវ សំផន ធ្លាប់ឃើញគាត់ ។

បូលី៖ កូនក្មួយ ពីណាគេពូ?

យ៉ុង៖ ខ្ញុំអត់ស្គាល់ទេក្មួយ ។ ប្រុសមួយ ស្រីមួយ ។

បូលី៖ ចុះកូនស្រីរបស់តាប៉ុល ពត ។

យ៉ុង៖ កាលខ្ញុំសែងនៅស្ទើរដែរ នៅតូច ។

បូលី៖ សែងដែរ ឬដើរ? ដើរជាមួយម៉ែវា?

យ៉ុង៖ បាទ!

បូលី៖ ហើយពេលដែលសែងមកនោះ តាប៉ុល ពតមាននិយាយអីទេ?

យ៉ុង៖ មាននិយាយអីទេ គាត់ថាតស៊ូ តាំងពីប្រវត្តិសាស្រ្តចេះតស៊ូនេះ មិនដែលចាញ់នរណា មកចាញ់អាមនុស្សហើយកំបុតជើង ហើយគាត់និយាយថា ទីក្រុង(ស្តាប់ពុំបាន) ឆេះកន្ទុយខ្លួនឯង ឆេះមែន ។

បូលី៖ គាត់និយាយចឹង?

យ៉ុង៖ បាទ! គាត់និយាយចឹង ។

បូលី៖ តាំងពីតស៊ូមក មិនដែលចាញ់ពីណាទេ! មិនគួរចាញ់មនុស្សកំបុតជើងទេ ។

យ៉ុង៖ បាទ!

បូលី៖ ខ្ញុំចង់បានសំដីតាប៉ុល ពត ផ្សេងៗទៀត អីអាចចាំបានទេអី ព្រោះសំដីសំខាន់ណាស់ ។

យ៉ុង៖ អត់ចាំផង ។

បូលី៖ មាន ដូចថាអីផ្សេងទៀតអីថាអីផ្សេងទៀតដែលអីអាចចាំបាន ដែលគាត់និយាយចឹងៗណា៎ ។

យ៉ុង៖ អត់ទេចាំបានតែប៉ុណ្ណឹង គាត់និយាយតែពាក្យប៉ុណ្ណឹង ។

បូលី៖ ពេលដែលសែងមក មួយយប់ទល់ភ្លឺចឹង គាត់និយាយច្រើនទេ ពេលហ្នឹង?

យ៉ុង៖ អត់រហូត ។ អត់ទេ! ដាក់អុកស៊ីសែនរហូត ។

បូលី៖ អ៎ូ! អុកស៊ីសែនរហូតណា៎!

យ៉ុង៖ បាទ! ដល់ពេលដែលគាត់ដកអុកស៊ីសែន ហៅខ្ញុំចេះតែអង្គុយជិតគាត់ និយាយពីរឿង ប្រវត្តិគាត់តស៊ូអី ដល់ពេលគាត់និយាយចឹង ដូចពាក្យខ្ញុំនិយាយអំបាញ់មិញ ប្រវត្តិគាត់តស៊ូ អាមេរិចកាំង គាត់តស៊ូឈ្នះ ស្អីក៏ឈ្នះ ហើយចាញ់ៗអាមនុស្សអន្តត់ជើងអីទៅណា៎ ។

បូលីៈ ពេល សម្រាកថ្ងៃហ្នឹង គាត់និយាយចឹងតែម្តង?

យ៉ុង៖ បាទ! និយាយចឹងពីប្រវត្តិគាត់ ។

បូលីៈ ពេលហ្នឹង គាត់ដកអុកស៊ីសែន?

យ៉ុង៖ ដកហើយ! ដល់តែថ្ងៃគាត់ មានដាក់ឯណា ។

បូលីៈ ដាក់តែពេលយប់ទេចឹង?

យ៉ុង៖ បាទ!

បូលីៈ អុកស៊ីសែនហ្នឹង រុកចូលតាមច្រមុះ ឬក៏គ្របលើច្រមុះចេះ?

យ៉ុង៖ កាលមុនដាក់ច្រមុះ ដាក់យប់ចេះតែញ្ញឹតៗ ស្មានតាស្អី ។

បូលីៈ ចឹងគាត់រស់ដោយសារអុកស៊ីសែនចឹង?

យ៉ុង៖ បាទ! គាត់ចាស់ហើយ គាត់! បើស្លាប់មាននរណាសម្លាប់គាត់ទេ ។ គាត់ឈរមើលប្រជាជន! ប្រជាជនយើងរត់ទៅ ឈរៗដាច់ខ្យល់ស្លាប់ ។ នៅជាប់នោះ!

បូលីៈ ចុះគេថាគាត់ត្រូវថ្នាំពុលថ្នាំអី សក់ខ្មៅសក់អីនោះ! ទេ ខ្ញុំមិនជឿទេ!

យ៉ុង៖ មិនជឿទេ ។ បើអ្នករត់ឡើងជាមួយគេនិយាយហើយ ។

បូលីៈ គេនិយាយថាម៉េច?

យ៉ុង៖ ដល់មើលប្រជាជនភ្លឹក! អាណិត អាសូរពិបាកណាស់ វាលំបាក! ដល់ឈរៗចឹងដាច់ខ្យល់ ស្លាប់នៅជាំដី ជាំនោះ ។

បូលីៈ ពេលហ្នឹង គាត់រត់ដែរទេ?

យ៉ុង៖ គាត់អត់រត់ទេ តែស្លាប់នៅជាំនោះ ។

បូលីៈ ផ្ទះដែលគាត់នៅហ្នឹង?

យ៉ុង៖ ទេ! មិនដឹងនៅទីណាទេ នេះខ្ញុំស្គាល់ ។

បូលីៈ ផ្ទះគាត់នៅក្បែរផ្ទះគាត់នេះ?

យ៉ុង៖ បាទ! ដឹងម៉េចទេ មិនសូវស្គាល់ដែរ ។

បូលីៈ ស្លាប់ដុតហ្នឹងកន្លែង?

យ៉ុង៖ បាទ!

បូលីៈ មេដឹកនាំមួយទាំងមូលណាពូ?

យ៉ុង៖ បាទ!

បូលីៈ ហើយដល់តែក្រោយតា ប៉ុល ពតស្លាប់ តា០៥,០៦ គេកាត់ទោស ប្រហារជីវិតអីមក ពេលហ្នឹងសភាពការយ៉ាងម៉េចខាងត្រពាំងប្រាសាទ ខាងអន្លង់វែង ឬក៏វាយគ្នាតទៀត?

យ៉ុង៖ អត់ទេ! សម្រុះសម្រួលអស់ ពួកនេះខាងត្រពាំងប្រាសាទអត់ទុកចិត្ត វារស់ដូចពួកខ្ញុំ ពួកអីណា ចូលរដ្ឋភិបាលនៅព្រះវិហារនោះ ។

បូលី៖ បានន័យថាតាម៉ុក គាត់គ្រប់គ្រងទាំងពីរហ្នឹងតែម្ដង?

យ៉ុង៖ តាម៉ុក គាត់ក្ដាប់រួម ។

បូលី៖ ក្ដាប់រួមហើយ?

យ៉ុង៖ បាទ!

បូលី៖ ប៉ុន្តែខាងត្រពាំងប្រាសាទ អត់ទុកចិត្តខាងអន្លង់វែងទេ យើងក៏នាំគ្នាចាប់ផ្ដើមរត់ម្ដងមួយៗទៅ?

យ៉ុង៖ ចាំមើលខ្ញុំនិយាយចេះ មុនដំបូងអើពេលផ្ដាច់ខ្លួនហើយ កងពល៨០១ចាប់នេះ ដា កែវនេះ ហើយបងពីនសឹករងព្រះវិហាររាល់ថ្ងៃ ។

បូលី៖ តាពីនហ្នឹង៩២០?

យ៉ុង៖ ៨០១ដែរ ។

បូលី៖ ៨០១ដែរ?

យ៉ុង៖ បាទ! ជាតិ ជុំយើងនេះណា ចៅហ្វាយស្រុកយើងពីដើម ៧១៩ គេចាប់ទៅដែរ ។ ចាប់ពួកហ្នឹងយកទៅដាក់នៅក្នុងទៅ ដល់ចឹងមានគេថា ពួកយើងនៅហ្នឹងវាប្រាប់ ប្រាប់ឲ្យរត់ ។ គាត់រត់ទៅព្រះវិហារទៅ ។

បូលី៖ ពីណាគេ?

យ៉ុង៖ នែ៎កជុំ, កែវ, ពីន រត់ទៅព្រះវិហារទៅ ។ បងស៊ិយអីកំបុតជើងហើយ យើងចេះតែទៅហើយគ្នាហ្នឹង ។

បូលី៖ ចឹងពេលហ្នឹង តាម៉ុក គាត់មានផែនការអីធំៗដែរ?

យ៉ុង៖ បាទ! កុំតែរត់នៅងាប់ ដល់ថ្ងៃស្លាប់ បានអ្នកឯហ្នឹងប្រាប់ ដូចថាអ្នកនៅយាមហ្នឹង ។

បូលី៖ អ៊ូ! អ្នកយាមគុកហ្នឹង?

យ៉ុង៖ បាទ! មិនដាក់គុកទេ យើងធម្មតា ប៉ុន្តែនែ៎កគេដូចថាអាណិតចឹងទៅ ក៏ប្រាប់ទៅ បងឯងត្រូវស្លាប់ហើយ ស្អែក ខានស្អែកហ្នឹង ក៏នាំប្រពន្ធកូនរត់ទៅអស់ រត់ទៅៗបានរស់ កុំអី! ឥលូវកែវ ទីប្រឹក្សាសម្ដេចដែរ ។

បូលី៖ ចុះពូថា គេហៅមេៗទៅរៀនហ្នឹង ពូមានទៅរៀនហ្នឹងគេពេលហ្នឹង?

យ៉ុង៖ ខ្ញុំទៅៗហើយរត់ហ្នឹងថា ទៅរៀនបានម្ដងនោះ ចេញពីរៀននោះ រត់ទៅ រត់ទៅផ្ដាច់ខ្លួននៅព្រះវិហារ ។

បូលីៈ ឌីមសារដែលគេបង្រៀននោះ គេមានបង្រៀនអីខ្លះ?

យ៉ុងៈ កាលហ្នឹងឌីមសារបង្រៀន ប៉ុល ពត ក្បត់ ។

បូលីៈ បង្រៀនតែប៉ុល ពតក្បត់ជាត់តែម្តងពូ?

យ៉ុងៈ បាទ!

បូលីៈ មានអីទៀតទេ ក្រៅពីនេះពូ?

យ៉ុងៈ មានអីទេ មានតែប៉ុណ្ណឹង ។

បូលីៈ ចុះរៀនតែប៉ុណ្ណឹងរៀនយូរម៉្លេះ?

យ៉ុងៈ ហៅទៅគ្រប់គ្នាទៅ ទៅបង្រៀន ប៉ុល ពតក្បត់ជាតិ ។

បូលីៈ ពីណាគេអ្នកបង្រៀន?

យ៉ុងៈ ពួកក្រោមៗនោះ ។

បូលីៈ មានតាផុនទេពូ មានអីទេពូ?

យ៉ុងៈ តាផុន តាអី ។

បូលីៈ នួន នៅមានទេ?

យ៉ុងៈ មានតែ ដូចថា គ្រូគេនៅសាលានយោបាយ អ្នកធ្វើការដាច់ដៃ ដាច់ជើងអីខ្លះមេក្មេង មេទាហាន មេអីពីដើម វរសេនាធំ វរៈអីហ្នឹង ។

បូលីៈ អ្នកបង្រៀនណាពូ?

យ៉ុងៈ បាទ!

បូលីៈ បង្រៀននៅសាលាណា?

យ៉ុងៈ នៅអន្លង់វែងនោះ ។ ទីតាំងមួយណាសាលា វិទ្យាល័យអន្លង់វែងរាល់ថ្ងៃ ឬក៏មួយណា អាហ្នឹងនៅអែបហ្នឹងនៅខាងលិច ។

បូលីៈ ខាងលិចវិទ្យាល័យអន្លង់វែង?

យ៉ុងៈ បាទ! នៅខាងលិចសាលានយោបាយ ។

បូលីៈ មុំសាលាស្រុកតា ។

យ៉ុងៈ ហ្នឹងហើយមុំហ្នឹង ជិតធនាគារអេស៊ីលីដាហ្នឹង ។

បូលីៈ ជិតហ្នឹង!

យ៉ុងៈ ខាងកើតហ្នឹងជាប់ហ្នឹងរបង ។

បូលីៈ ផ្ទះសំណាក់សោភារាល់ថ្ងៃ តាមមើល ។

យ៉ុងៈ មិនដឹងឯណា ។

បូលី៖ មានរោងគេមួយពូ?

យ៉ុង៖ ហ្នឹងហើយទីហ្នឹង ហ្នឹងហើយសាលានយោបាយ ។

បូលី៖ រៀន ប៉ុន្មានថ្ងៃពូ?

យ៉ុង៖ ជួនកាល៣ថ្ងៃ! ៤ថ្ងៃ!

បូលី៖ ចុះរៀន៤ថ្ងៃ ៣ថ្ងៃហ្នឹង រៀនតែប៉ុល ពតក្បត់មួយចឹង?

យ៉ុង៖ បាទ!

បូលី៖ បាទ! ខ្ញុំមសារអីខ្លះពូ បានជាគេនិយាយច្រើនម្ល៉េះ គេឡើងសូត្រឲ្យយើងស្ដាប់តែម្ដង ឬក៏ឲ្យយើងពិភាក្សាគ្នា?

យ៉ុង៖ គេពន្យល់យើង ហើយយើងពិភាក្សាគ្នា តាមក្រុម តាមអីហ្នឹងហ្នឹង ។ វានិយាយថា ប៉ុលក្បត់ជាតិតែប៉ុណ្ណឹងសំខាន់ ។

បូលី៖ ចុះ ផែនការទៅថ្ងៃអនាគតផ្សេងទៀតមាននិយាយទេ ត្រូវតស៊ូរំដោះជាតិមានទេ?

យ៉ុង៖ កាលខ្ញុំទៅរៀននោះ ដូចអត់មាននិយាយអីចឹងទេ ។

បូលី៖ ប៉ុន្តែក្នុងចិត្តពូ ពូមានសង្ឃឹមថារំដោះជាតិមកវិញបានទេ?

យ៉ុង៖ អត់ទេ! ខ្ញុំអត់ទេ ។

បូលី៖ អស់សង្ឃឹមតែម្ដងណ៎?

យ៉ុង៖ ប៉ុល ពតនិយាយ ខ្ញុំមិនទីងហ្នឹងគាត់ទេ គាត់ថា យើងត្រូវផ្សះផ្សាជាតិ ត្រូវទំនាក់ទំនងជាមួយរដ្ឋាភិបាលនៅប្រាសាទព្រះវិហារ ។ គម្រោងហ្នឹងណ៎ជាដំណោះស្រាយ ។

បូលី៖ តាប៉ុល ពត ទៅចរចាជាមួយរដ្ឋាភិបាលនៅប្រាសាទព្រះវិហារ?

យ៉ុង៖ បាទ! អាហ្នឹង ខ្ញុំដឹង! គម្រោងផែនការរបស់គាត់ ។

បូលី៖ នរណាអ្នកចរចារ?

យ៉ុង៖ កាលហ្នឹងអ៊ីខៀវ សំផនអីហ្នឹង គាត់អ្នកទៅ ។

បូលី៖ ខៀវ សំផន?

យ៉ុង៖ បាទ!

បូលី៖ ហើយនរណាអ្នកទៅទៀត?

យ៉ុង៖ ដឹងពីណា! គ្រាន់តែពួកគម្រោងផែនការចឹង ខ្ញុំដឹងពីមេៗកងពល ។

បូលី៖ ទេព ខុណាល់ មានទេ?

យ៉ុង៖ កាលហ្នឹងអាចទៅហើយ ទេព ខុណាល់ អាចទៅជំនាន់ហ្នឹង ព្រោះទេព ខុណាល់នៅក្រសួងការងារ ។

បូលីៈ ចរចាជាមួយស្ថាប័ន ចរចាខាងភាគីណា ភាគីគណៈបក្សប្រជាជន?

យ៉ុងៈ គណៈបក្សប្រជាជនហ្នឹង ។

បូលីៈ មិនមែន ហ៊ុន សុិនប៉ិច?

យ៉ុងៈ អត់ទេ! គណៈបក្សប្រជាជន ។

បូលីៈ ហ្ញ៎! ដែលថាចរចាយកប្រាសាទព្រះវិហារនោះហ៎?

យ៉ុងៈ បាទ! គម្រោងមិនទាន់បានចរចាណា៎ តាម៉ុកវាយហ្នឹងថា ។

បូលីៈ យល់ហើយពូ យល់ហើយ ។

យ៉ុងៈ គ្រាន់តែគម្រោង បានតាម៉ុកដឹងល្បិច ខ្លាចចរចាមុន វាយរដ្ឋប្រហារ ។ ហ្នឹងខ្ញុំទៅប្រជុំនៅជាមួយខាងក្រោម ។

បូលីៈ មេមួយណាពូ?

យ៉ុងៈ ខ្មោចបងធន ខ្មោចអីហ្នឹង វរសេនាធំគេប្រជុំ ។

បូលីៈ គេថាម៉េចទៅកាលហ្នឹង?

យ៉ុងៈ គេថាគម្រោងយើង ទាក់ទងជាមួយរដ្ឋាភិបាលដើម្បីបង្កើតរណសិរ្ស រណៈអីហ្នឹងណា៎ ។

បូលីៈ តាម៉ុក គាត់ធ្លាប់ចរចាជាមួយញ៉ឹក ប៊ុនឆៃដែរ?

យ៉ុងៈ ហ្នឹងហើយវាចឹង បានវាយគ្នា ប្រាប់អូនឯងចឹងណា៎ ។

បូលីៈ នៅវាំងយើង កាលហ្នឹង កាលហ្នឹងអេលីកុបទ័រចុះ បាញ់ឆេះនោះ ។ នរណាអ្នកបាញ់កាលហ្នឹង?

យ៉ុងៈ តាគេម តាអីហ្នឹង ប៉ុន្តែងាប់អស់ហើយពួកហ្នឹង ។

បូលីៈ ប៊ុនតាគេម អ្នកចរចាជាមួយញ៉ឹក ប៊ុនឆៃយ៉ាងម៉េច បានទៅចរចា?

យ៉ុងៈ ឥលូវងាប់អស់ហើយ ។ នេះអ្នក ភីលុត(pilot) អីស្អីមួយនោះ ។ បង០៩ គាត់យកមកនៅផ្ទាល់តាបាននៅរស់ ។

បូលីៈ ហ្ញ៎! តា០៩ អ្នកចាប់មក?

យ៉ុងៈ បាទ! អ្នកយកមក ។

បូលីៈ ភីលុត(pilot) ៩នាក់ហ្នឹងហ៎ពូ?

យ៉ុងៈ បាទ! ហ្នឹងហើយ គាត់អ្នកយកមកតើ!

បូលីៈ ដែលថានៅរស់ហ្នឹង?

យ៉ុងៈ បាទ!

បូលីៈ ក្រៅពីហ្នឹងស្លាប់ទាំងអស់?

យ៉ុង៖ ហើយស្អី លឹម ពិន មួយនោះក៏នៅរស់ដែរ ។

បូលី៖ លឹម ពិន?

យ៉ុង៖ បាទ!

បូលី៖ ភីលុត(pilot) ហ្នឹងហេ៎?

យ៉ុង៖ អត់ទេ! ឯហ្នឹងខាងនេះទេ ខាងហ៊ុន សុិនប៊ុិចណ៎ា នៅដែរ ។ ភីលុត(pilot) នៅទាំងអស់ អីតកាលហ្នឹង?

បូលី៖ ភីលុត(pilot) ពួសួរថាដូចនៅទាំងអស់ បង០៥ អីមកយក ។ ខ្ញុំសម្ភាសន៍អ្នកនៅខាង អន្លង់វែង គេនិយាយបេះពូ គេថាតាម៉ុកចរចាជាមួយ ហ៊ុន សុិនប៊ុិច ។ នៅហ៊ុន សុិនប៊ុិចហ្នឹង កាលមាន ញឹក ប៊ុនឆៃ មានខាន់ សាវឿន មានហែម ប៊ុនហេង ចៅហ្វាយខេត្តរងទី២ហ្នឹងណា ។

យ៉ុង៖ បាទ! គេនិយាយត្រូវហើយណ៎ ។

បូលី៖ ហើយពេលដែលកំពុងចរចាហ្នឹង តា០៥បានបាញ់ផ្តក់ចូលទៅកន្លែងចរចាហ្នឹង ។

យ៉ុង៖ ខ្ញុំអត់ជឿទេ!

បូលី៖ ហើយបានឆេះ យន្តហោះ ហើយស្លាប់ ហែម ប៊ុនហេង ចៅហ្វាយខេត្តទី២សៀមរាបណា ហើយស្លាប់អ្នក ចរចាខាងហ៊ុន សុិនបិច ទាំងអស់ ។ ភីលុត(pilot) ៤នាក់ហ្នឹង យញមក អន្លង់វែង តា០៥ អ្នកចាប់មក ។ ដល់ចឹងធ្វើឲ្យការចរចាបរាជ័យ ដោយសារតា០៥ហ្នឹង, ប៉ុល ពត អត់ចង់ឲ្យចរចា! ពូយល់ឃើញថាម៉េចដែរចឹង?

យ៉ុង៖ ភីលុត(pilot) នោះ កុំតែបានតា០៥ទេ កុំអីផាប់ដែរហ្នឹងណ៎ ។

បូលី៖ ប្តុក៏ការចរចាមាន២ចំណែក ទី១ខាងតាម៉ុកចរចាជាមួយហ៊ុន សុិនប៊ុិច, ទី២ខាងតាប៉ុល ពត សហការជាមួយគណបក្សប្រជាជន ។

យ៉ុង៖ អាហ្នឹងដែលធ្វើរដ្ឋប្រហារគ្នានោះ ។

បូលី៖ មួយចរចារៀងខ្លួនទៅ ម្នាក់ចរចារៀងខ្លួនទៅ អត់ពិភាក្សាគ្នាសិនទេពេលហ្នឹង?

យ៉ុង៖ បាទ!

បូលី៖ ហ្វូ៎! ពេលហ្នឹង ហើយដែលញឹក ប៊ុនឆៃដឹកអាវុធ ដឹកអីមកយកជួយតាម៉ុក វាយជាមួយប៉ុល ពត?

យ៉ុង៖ បាទ! ហ្នឹងហើយ ។ ក្រោយមកថ្ងៃ៥ ថ្ងៃ៦ជាមួយពួកញឹក ប៊ុនឆៃផ្តាច់ខ្លួនមក នៅជាមួយ តាម៉ុក ។

បូលី៖ បាទ! ត្រូវហើយ ឃើញវីដេអូញឹក ប៊ុនឆៃមកជួប សុំឲ្យតាម៉ុកជួយណ៎ ។

យ៉ុង៖ បាទ!

បូលីៈ ប៉ុនពេលហ្នឹង តា ប៉ុល ពត គេចាប់ខ្លួនបានហើយ?

យ៉ុនៈ បាទ! គាត់ចាប់ហើយ ។

បូលីៈ មានផែនការលើប្រាសាទព្រះវិហារត្រូវបរាជ័យ?

យ៉ុនៈ បាទ! បរាជ័យ ដូចខ្ញុំនិយាយមិញហើយ ។ ផែនការបរាជ័យហើយដល់ពួកនេះវាយនេះទៅ យើងបានចរចាគ្នានៅលើព្រះវិហារហើយ ។

បូលីៈ ចឹងបានខ្ញុំឆ្ងល់ ខៀវ សំផន គាត់អ្នកស្មោះស្ម័គ្រជាមួយប៉ុល ពត រឿងអីទៅជា ខៀវ សំផន ទៅជាចរចា តាមបញ្ជាតាម៉ុក?

យ៉ុនៈ អត់ទេ!

បូលីៈ តាមបញ្ជាប៉ុល ពតទេចឹង?

យ៉ុនៈ បាទ!

បូលីៈ មួយCPP មួយ ហ៊ុន ស៊ិនប៉ិច?

យ៉ុនៈ បាទ!

បូលីៈ កុំតែដដែកជាមួយពូ កុំអីអត់ដឹងសោះរឿងនេះ ទើបតែភ្លឺជាមួយពូទេនេះ ។

យ៉ុនៈ ខ្ញុំប្រាប់អូនឯងណា៎! នៅនេះគណៈបក្សនែ៎ក ហ៊ុន សិនប៉ិច និងគណៈបក្សប្រជាជនណា៎ ។

បូលីៈ បាទ!

យ៉ុនៈ និយាយគណៈបក្សប្រជាជន ហើយពួកខ្ញុំនិយាយដូចថាវាស៊ីខ្សែគ្នាណាស់ អត់មានរឿងអីទេ ហើយគណៈបក្សហ៊ុន ស៊ិនប៉ិចនោះនិយាយដូចមិនត្រូវគ្នាទេ ។

បូលីៈ វាយ៉ាងម៉េចពូ បានជាមិន?

យ៉ុនៈ មិនដឹងយ៉ាងម៉េចទេខ្ញុំ ដូចជាឆ្ងល់ដែរអារឿងគណៈបក្ស ទាហានខាងគណៈបក្សប្រជាជន ដូចជាឆាប់ត្រូវគ្នា ។

បូលីៈ ពូមានដែលចូលទៅចុះឈ្មោះធ្វើការជាមួយគេទេ ជាមួយតាខៀវ សំផន តាអី?

យ៉ុនៈ ខ្ញុំហ៎?

បូលីៈ បាទ! មានដែល ដូចថាការពារគាត់ទៅចរចាទេ?

យ៉ុនៈ អត់ដែរទេ! ខ្ញុំមិនដែរបានទៅ ។

បូលីៈ គាត់ដឹងតាមគេមក?

យ៉ុនៈ បាទ! ខ្ញុំដឹងមេៗក្រោមៗដែរ ។

បូលីៈ តាសារឿន តាពីនហ្នឹង និយាយប្រាប់ដែរ?

យ៉ុង៖ បាទ! គាត់ហៅវរសេនាធំ គាត់លើកហេតុផល! ខ្ញុំចង់បញ្ចប់សង្គ្រាមអីចឹងទៅដោះស្រាយជាមួយរដ្ឋាភិបាល ការពាររណសិរ្ស គ្រាន់និយាយចឹងណា៎ ។

បូលី៖ ក្រោយពេលដែលតាម៉ុក ហៅពូទៅរៀនសូត្រអីហើយ ពូដឹងថាបើបន្តទៀតហ្នឹងស្លាប់ហើយ!

យ៉ុង៖ ស្លាប់នាំគ្នារត់ចូលក្នុងរដ្ឋាភិបាល ។

បូលី៖ រត់ហ្នឹងយើងប្រកាសប្រាប់គ្នា ឬយើងនៅដោយសម្ងាត់?

យ៉ុង៖ ជួបគ្នា ពួកខ្ញុំទៅណា៎ គ្នាជិត១០០នាក់ ។

បូលី៖ ប្រជុំនៅម្តុំណា៎?

យ៉ុង៖ នេះកាលតាអែបនេះ កាលវាយជាមួយរដ្ឋាភិបាលនេះ ប៉ុនពួកអានេះ ពួកខ្ញុំអាងមេៗទៅហើយទាក់ទងវាជាប់ ប៉ុន្តែវាទៅទាក់ទងគ្នាជាប់ ។

បូលី៖ តាឈូក តាកែវអីហ្នឹង?

យ៉ុង៖ បាទ! យកក្មេងៗទៅហ្នឹង មកទាក់ទងគ្នារហូត ។

បូលី៖ ដោយសារយើងមានអ្នកខាងក្នុងរួចហើយ ។

យ៉ុង៖ បាទ! មានខ្នងរួចទៅហើយ ។

បូលី៖ ចឹងឲ្យពូប្រមូល!

យ៉ុង៖ ទៅៗ កូនខ្ញុំទៅ ជាមួយជាកែវកូនខ្ញុំទៅជាមួយ ជា កែវ កាលហ្នឹង វានៅវរៈគាត់ ។

បូលី៖ មួយណា?

យ៉ុង៖ នៅចុងភូមិនោះ នៅជាមួយ ។

បូលី៖ អង្គរក្សរបស់ជាកែវហើយណ៎?

យ៉ុង៖ បាទ! ជំនាន់ខ្មែរក្រហម នៅជាមួយគាត់ ។

បូលី៖ ចឹងពូចាប់ផ្តើមប្រមូល ប្រមូលកូនអីរត់ទៅបណ្តោយ ។

យ៉ុង៖ កូនអត់ទៅទេ! តាម៉ុក យកដាក់គុកទៀត ។

បូលី៖ ទៅតែពូទេអីចឹង?

យ៉ុង៖ បាទ! ទៅតែប្រុសហ្នឹង ។ ប្រពន្ធកូនក៏តាម៉ុក គេចាប់យកទៅនៅអន្លង់វែងហ្នឹង ។

បូលី៖ ចុះពេលដែលពូរត់ទៅហ្នឹង គេអត់មានវាយស្ការត់អីទេហ៎?

យ៉ុង៖ អត់ទេ!

បូលី៖ ខាងតាម៉ុក?

យ៉ុង៖ អត់! អត់មានតាម ព្រោះខ្ញុំខ្លាំងៗដែរ ។

បូលី៖ មានកាំភ្លើងដែរ ។

យ៉ុង៖ ចុះមានកាំភ្លើងគ្រប់ដៃ ។ កាំភ្លើតូច កាំភ្លើងធំអីនោះ ។

បូលី៖ រត់ទៅហ្នឹង រត់ទៅតាមច្រកណា ។

យ៉ុង៖ ខ្ញុំទៅតាមស្រអែម ទៅលើត្នោតប៉ាយ ។

បូលី៖ ដល់ពេលទៅ ទៅជួបហ្នឹងទាហានរដ្ឋាភិបាលនៅម្ដុំហ្នឹងទៅ ។

យ៉ុង៖ ដល់ចឹងបងដាកែវក៏ទទួលនៅត្នោតប៉ាយ ។

បូលី៖ បងដាកែវ គាត់ចុះមកទទួល?

យ៉ុង៖ បាទ! ហើយមកជាមួយរដ្ឋាភិបាល ។ ដល់តែពួកខ្ញុំ មកដល់ហ្នឹងហើយ ពួកនៅជួបមុខដែរ តាម៉ុក បញ្ជាឲ្យពួកខ្ញុំទៅវាយហ្នឹង ទាហានរដ្ឋាភិបាលគេហៅបងអើយទៅឆ្ងាយៗ មកនេះមិនមក! ដល់ចឹងហើយ យើងទំនាក់ទំនងគ្នានេះហើយ មានហានចូលណា៎ អាហ្នឹងមុនទៅយើងសួរគេអស់ហើយ ។ ឥលូវ ខ្ញុំចូលមុខនេះ ចូលផុតទៅ ដល់ចឹងអាខ្លះ ក្មេងៗនោះថាមិនបាច់ទៅនោះទេឆ្ងាយណាស់ ចូលមុខហ្នឹង ទុកខ្ញុំទៅតែឯង ។ អាខ្លះគ្នាស្ម័គ្រចិត្តចឹងណា៎ ទៅដោះអាវទៅដើរទៅទំនាក់ទនងគ្នាទៅ ។

បូលី៖ ចូលមុខហ្នឹងចូលម្ដុំណា៎?

យ៉ុង៖ ម្ដុំថ្មធំ ម្ដុំអី យើងមិនសូវ(ស្ដាប់ពុំបាន) ។

បូលី៖ ក្បែរៗស្រអែមយើងនៅទេ?

យ៉ុង៖ បាទ! ខាងសអែមហ្នឹង ។

បូលី៖ ដល់ទៅជួបតា(ស្ដាប់ពុំបាន) ?

យ៉ុង៖ បាទ! ជួបគេអូទៅគាត់ទៅ ដល់ហើយអូនអើយដាច់ទឹក១ថ្ងៃ ។

បូលី៖ ប៉ុន្មាននាក់ ពេលពូទៅហ្នឹង?

យ៉ុង៖ ទេ! ៥០ ទៅ៦០នាក់ដែរ ។

បូលី៖ ច្រើនដែរ ។ ប៉ុន មិនមែនទៅតែមួយសារហ្នឹងណា៎ពូ?

យ៉ុង៖ ទៅតែពួកខ្ញុំទេ ។ ទៅតែម្ដងបាត់ហើយ ឬក៏មានអ្នកមានបន្តកន្ទុយទៀតទេ?

បូលី៖ អត់មានទេ! ទៅតែពួកខ្ញុំមួយ(ស្ដាប់ពុំបាន)

យ៉ុង៖ ដល់តែពេលយើង ទៅដល់ហើយជួប តាកែវ ជួបតាជុំអីហើយ យើងរៀចំផែនការផែនការវាយមកវិញ?

បូលី៖ មុនដំបូងរៀបចំផែនការវាយ នេះអ៊ីង លៀងនេះវែអត់ទាន់ដាច់ទេណា៎ ។ គាត់រដ្ឋាភិបាលនោះអត់ហានសម្រេច ដល់ចឹងគាត់ថាហ៎ជួយខបត្តម្ភសម្ភារមក ទៅតែពួកខ្ញុំក៏បានដែរ ។

យ៉ុង៖ ចឹងហ៎ពូ?

បូលីៈ និយាយចិនតែម្តង?

យ៉ុងៈ ពួកខ្ញុំ!

បូលីៈ នរណានិយាយចិន?

យ៉ុងៈ អ៊ុន លៀនហ្នឹងណា៎ ។

បូលីៈ គាត់នៅហ្នឹង?

យ៉ុងៈ គាត់ឈឺទារុនទ្រាហើយ ។

បូលីៈ គាត់និយាយចិនហេ៎?

យ៉ុងៈ បាទ! ថាចិនសាចុះ សាឡើងក៏ ខាងតាដឹក តាអីក៏ឯកភាពទៅក៏ឲ្យមក មកជំហានដំបូងក៏វាយគ្នានៅទំនប់ដាច់នោះ ។ កាលហ្នឹងពួកតាម៉ុក វាយនៅទំនប់ដាច់ ពួកខ្ញុំនេះក៏មក ។ មកនៅបាន២ថ្ងៃ ។ ពួកខ្ញុំបាន ដកទៅវិញ ពួកខ្ញុំដកដល់កណ្តាលផ្លូវ ពួកនោះផ្តាច់ខ្លួនក៏បកមកវិញចុះដល់អូរស្មាយ ។

បូលីៈ ហ៊ូ! ពួកបូផាណា ។

យ៉ុងៈ បាទ! ពួកបូផាណា ។

បូលីៈ តាថាំង តាទុំអី!

យ៉ុងៈ បាទ! ហ្នឹងហើយ ។ ដល់ខ្ញុំថយពី២នាក់ហ្នឹងទៅ ដល់ក្បែរត្នួតហ្នឹង គេថាអ៊ូអន្លង់វែងផុះហើយៗ

បូលីៈ វាយបកមកវិញទៀត ។

យ៉ុងៈ បកមកវិញទៀត រហូតទៅដល់ ដើរទៅដល់អូរស្មាយ! ទៅដល់អូរស្មាយចេះតែមានខ្សែរបស់នៅហ្នឹង ។

បូលីៈ ខ្សែពួ?

យ៉ុងៈ បាទ! គេអូទាក់ទងនោះ ។

បូលីៈ វាយប៉ុន្មានថ្ងៃ ពេលមកវាយដំបូង?

យ៉ុងៈ មកដំបូងវាយតែមួយថ្ងៃ ។

បូលីៈ កម្លាំងប៉ុន្មាននាក់?

យ៉ុងៈ កម្លាំងច្រើនដែរ ។ ទាហានរដ្ឋាភិបាលអី ច្រើនណាស់ ។

បូលីៈ មានខាងរដ្ឋាភិបាលដែរ?

យ៉ុងៈ បាទ!

បូលីៈ នរណាគេបញ្ជាការរួម វាយពេលហ្នឹង?

យ៉ុងៈ កាលហ្នឹងតាដឹក ។

បូលី៖ ស្រីដឹកហេ៎?

យ៉ុង៖ បាទ!

បូលី៖ បញ្ជាការធំនែក៎?

យ៉ុង៖ បាទ!

បូលី៖ បើខាងយើងនរណាគេបញ្ជាការ?

យ៉ុង៖ កាលហ្នឹង មានអ៊ឹង លៀង នេះខ្វាបី ខ្វាអីហ្នឹង?

បូលី៖ នរណាគេខ្វាបី?

យ៉ុង៖ នេះចាន់ថន ។ នៅកងពលលេខ៣នោះហើយ!

បូលី៖ ចាន់ថននេះ ក្រែងរដ្ឋាភិបាលដែរ?

យ៉ុង៖ បាទ! ហ្នឹងហើយកាលហ្នឹង ។

បូលី៖ ដែលដឹកនាំចូលមកនេះផ្ទាល់ណា?

យ៉ុង៖ បាទ! ហ្នឹងហើយ ។

បូលី៖ ប៉ុន្មាននាក់ទាំងអស់?

យ៉ុង៖ ដឹកនាំផ្ទាល់តែម្តង មានតែមេក្រោមៗនេះ ។ ចាន់ថននេះនៅឯក្រោម មានតែវរសេនាតូច វរសេនាធំ!

បូលី៖ សរុបទៅ មានប៉ុន្មានកម្លាំង? ១០០ទេមើលទៅ?

យ៉ុង៖ ទេមិនមែន១០០ទេ! ២០០ ។

បូលី៖ ២០០ណ៎ ។

យ៉ុង៖ បាទ!

បូលី៖ មានកាំភ្លើងធំ មកជាមួយទេ?

យ៉ុង៖ អត់ទេ! អាហ្នឹងមានត្រឹមបេ(អាបេ) អាវុធថ្មើរជើងនោះ ។ រថក្រោះ អត់មានទេ! វាយទៅចូលអូរស្មាយ ។

បូលី៖ ចុះកម្លាំងនៅខាងនេះរបស់តាម៉ុកនរណាគេ ដែលវាយជាមួយពូ ពេលហ្នឹង?

យ៉ុង៖ មានពួកនេះ ពួក៧៨៥អី ។

បូលី៖ ហ៊ូ! ៧៨៥?

យ៉ុង៖ បាទ! ៧៨៥ ពួកតាញ៉ែន តាអីហ្នឹងណា៎,៦១២, ៩១២ ។

បូលី៖ ៧៨៥,៦១២,៩១២ ចុះ៦១៦ មានទេ?

យ៉ុង៖ ៦១៦ មាន ។

បូលី៖ ៩៩០អី?

យ៉ុន៖ ៩៩០ ពួកឯលិចហ្នឹង ពួកអន្លង់វែង ។

បូលី៖ អន្លង់វែង ហើយណ៎?

យ៉ុន៖ ៩៩០ ពួកតាពីម ។

បូលី៖ តាពីម?

យ៉ុន៖ បាទ!

បូលី៖ និយាយទៅ៩៨០ វាបែកជា២ចេះ! ដល់ពេលផ្តាច់ខ្លួន មួយមកនៅជាមួយតាម៉ុក ។

យ៉ុន៖ បាទ! ហ្នឹងហើយ ។

បូលី៖ ហើយ២ហ្នឹងវាយគ្នាចេះ ។ ហើយពេលខាងពួមាន៨០១, ៩២០ ផ្តាច់ខ្លួន! ៤១៧អីនែក ហើយមកវាយជាមួយពួក៧៨៥អី ៦១២, ៩១២ ។

យ៉ុន៖ ៦១៦!

បូលី៖ ៦១៦?

យ៉ុន៖ ៦១២នេះ! នៅខាងនេះ ពួកតាហឿននេះ ។

បូលី៖ ពួកកតាហឿនហេ៎?

យ៉ុន៖ បាទ!

បូលី៖ នៅខាងផ្តាច់ខ្លួនដែរ?

យ៉ុន៖ បាទ!

បូលី៖ ចឹងអ្នកផ្តាច់ខ្លួន មាន៧៨៥!

យ៉ុន៖ ៦១៦!

បូលី៖ ៦១៦ ពួកតាញ៉ន?

យ៉ុន៖ បាទ! ៩១២!

បូលី៖ ចឹងវាយគ្នាឯងចឹង?

យ៉ុន៖ បាទ! វាយគ្នាឯង ។

បូលី៖ ដល់វាយបាន១ថ្ងៃ ពូដកទៅវិញសិន?

យ៉ុន៖ បាទ! ខ្ញុំដេកឡើង២ពេលយប់ ។ ដក់កាលហ្នឹងបងជុំអី ក្រោយ! ដល់វាយកន្ទុតហ៎ វាយនែក ពួក ៦៨០ ផ្តាច់ខ្លួនដែរហើយក៏មកវិញដែរ ។ ពួកខ្ញុំអីរត់ទីណាត់ទីណែង៦៨០ហ្នឹង មិនដឹងខ្លួន ។ នៅអន្លង់វែងហ្នឹង ទៅមុខមន្ទីរពេទ្យហ្នឹង មន្ទីរពេទ្យ យើងរាល់ថ្ងៃនេះហ្នឹង គាត់នៅហ្នឹង ១២ គ្រួសារ ។

បូលី៖ អូរជីក?

យ៉ុង៖ បាទ! រត់មកទីណាត់ទីណែង! មកដល់ផ្ទះបានមួយយប់ ខ្ញុំបានមួយយប់បានខ្ញុំទៅដល់ដែរ ។

បូលី៖ ទៅដល់ជួបតែម្តង?

យ៉ុង៖ បាទ! ជួបនៅផ្ទះដែរ ។

បូលី៖ មានយំ មានអីឲ្យបគ្នាទេ?

យ៉ុង៖ អត់ទេ!

បូលី៖ ហើយទៅពូ ពេលទៅជួប ទៅយកគាត់មកតែម្តង?

យ៉ុង៖ បាទ! មកដេកបាន១យប់ បានមកលួកល្អឹន មនុស្សពេញទឹក ពេញដី កាលហ្នឹងមួយជំនាន់ ។

បូលី៖ នៅទំនប់ដាក់យើងនេះ?

យ៉ុង៖ បាទ! នៅទំនប់ដាច់យើង ឡើងណែនហៀរ ចុះតាំងពី៩២០អីមក មកនៅជុំគ្នាទាំងអស់ ។ ហើយខាងអន្លង់វែង អូរបៃតាប់ អូរអី ។ ដល់ចឹងទៅខាងកើតនោះ ក៏មកនៅទៅ ។

បូលី៖ អន្លង់វែង គេទៅអូរបៃតាប់នែក៎?

យ៉ុង៖ បាទ!

បូលី៖ ដល់ពេលខាងត្រពាំងប្រាសាទយើង មកនៅទំនប់ដាច់?

យ៉ុង៖ បាទ!

បូលី៖ នៅគៀកម្ល៉េះពូ ម៉េចក៏មិនទៅឲ្យឆ្ងាយ ខ្លាចខាងទំនប់មកវាយទៀត?

យ៉ុង៖ នៅហ្នឹង ព្រោះកម្លាំងនៅតែហ្នឹងដែរ ។

បូលី៖ ហ៊ូ! ដោយសារពួកតាម៉ុក ឡើងភ្នំហើយ ។

យ៉ុង៖ បាទ! ពួកយើងឡើងទៅមុខហើយ ហើយចេះតែវាយគ្នាទៅ! វាយដេញៗ ជាមួយហ៊ុន ស៊ិនប៉ិចទៅអីចឹងទៅ ។ ហ៊ុន ស៊ិនប៉ិចជាមួយតាម៉ុក តាអីចឹងទៅ ។

បូលី៖ ហ៊ុន ស៊ិនប៉ិច ម៉េចទៅ?

យ៉ុង៖ កាលនោះ ហ៊ុន ស៊ិនប៉ិច មិនជាមួយតាម៉ុក កាលហ្នឹងថ្ងៃ៥, ថ្ងៃ៦នោះ ។ ពួកនោះផ្តាច់ខ្លួនញឹក ប៉ុនតែ មិននៅជាមួយតាម៉ុក វាយជាមួយពួកខ្ញុំ ពួកអីហ្នឹង ។

បូលី៖ ចឹងខាងអន្លង់វែង គេទៅអូរបាយតាប់នែក៎?

យ៉ុង៖ បាទ!

បូលី៖ ខាងត្រពាំងប្រាសាទ មិនទៅទំនប់ដាច់?

យ៉ុង៖ បាទ!

បូលី៖ ហើយកម្លាំងផ្តាច់ខ្លួនហ្នឹងវាយផ្គុំគ្នា ទៅចាប់ដៃនៅអន្លង់វែង?

យ៉ុង៖ បាទ!

បូលី៖ ឬក៏ចាប់នៅម្ដុំណា?

យ៉ុង៖ អន្លង់វែង!

បូលី៖ ចាប់ដៃគ្នានៅអន្លង់វែង?

យ៉ុង៖ នៅម្ដុំជួរស្រះឈូក ស្រះអីហ្នឹង។

បូលី៖ ចាប់វាយពីនេះទៅ?

យ៉ុង៖ បាទ! ចាប់វាយតាំងពីនេះទៅ។

បូលី៖ ហើយកម្លាំងតាម៉ុក ឡើងភ្នំ?

យ៉ុង៖ ឡើងភ្នំ ហើយអាខ្លះមកចាំវាយទប់ ទល់ជាមួយយើងទៅពីនេះទៅ។

បូលី៖ ខាងតាម៉ុក មាននរណាខ្លះពូ? មានតាវ៉ាន់ កុសល ទៅនៅភ្នំជាមួយតាម៉ុកដែរ អត់ទេ?

យ៉ុង៖ ទៅ!

បូលី៖ ទុយ សារ៉េត?

យ៉ុង៖ ទៅយូរហើយ ទៅខាងរដ្ឋាភិបាលយូរហើយ។

បូលី៖ ឥលូវមានវ៉ាន់ កុសល មានពីណាទៀត ដែលទៅជាមួយតាម៉ុក កាលហ្នឹង?

យ៉ុង៖ កាលហ្នឹង មាន៨០ ហៅសឿនណាំនៅជ្រៃដើមថ្មីង។

បូលី៖ ពីណាទៀតពូ?

យ៉ុង៖ ទេ! មេៗច្រើនដែរ។ មេៗកងពល ពួកនោះនៅហ្នឹងទាំងអស់។

បូលី៖ តា ង៉ំ តាអី?

យ៉ុង៖ បាទ! តា ង៉ន់ ហ្នឹងមេគេធំហើយនៅហ្នឹង។

បូលី៖ ធំហើយ! ចុះតាខៀវ សំផនអី ចាន់ យូរ៉ាន់អីទៅណាទៅ?

យ៉ុង៖ គាត់នៅលើនោះឯង។

បូលី៖ ឡើងទៅ ហ៊ូ ណាយ អីនោះដែរ?

យ៉ុង៖ បាទ! ទៅហ្នឹងទាំងអស់។

បូលី៖ ទេព ខុណាល់អី?

យ៉ុង៖ បាទ! ទៅទាំងអស់។

បូលី៖ ខ្ញុំបានព័ត៌មានពីពូច្រើនហើយនេះ ព្រោះខ្ញុំវាអត់ច្បាស់សោះអារឿង វាយចូលចឹងមកណា។ ប៉ុន្មានថ្ងៃ តាមតាម៉ុក រត់ឡើងភ្នំ ពូវាយប៉ុន្មានថ្ងៃ?

យ៉ុង៖ ទៅវាយយូរដែរ។

បូលីៈ ចាប់ផ្ដើម ពីថ្ងៃទី១មកណ៎ា ។

យ៉ុនៈ បាទ! វាយយូរហើយ ។

បូលីៈ ១ខែទេ?

យ៉ុនៈ ចូល១ខែ ទៅ២ខែហើយយ៉ាង បានទៅ ។ វាយចាប់ពីក្បាលទន្សោងនេះទៅ ដេញទៅចេះវិញ ។

បូលីៈ ហ៎ូ! វាយទៅក្បាលទន្សោងទៀត?

យ៉ុនៈ បាទ! ឡើងទៅលើ ពួកយើងវាយទៅក្បាលទន្សោងដេញទៅដាំវិញ ។

បូលីៈ ដេញទៅដាំវិញ?

យ៉ុនៈ បាទ!

បូលីៈ ហ៎ូ!ចឹង ពួវាយពីនេះមកចឹង?

យ៉ុនៈ បាទ!

បូលីៈ ក្បាលទន្សោងពីកើតទៅ?

យ៉ុនៈ បាទ! ពីកើតទៅ ។

បូលីៈ ចុះ យើម ដាន់ណា វាយពីណាទៅ?

យ៉ុនៈ គាត់វាយឡើងចំហៀងខាងនែក៎! វាយពីខាងនេះទៅណ៎ា ។

បូលីៈ មកដល់ដាំស្រុងនេះវិញ?

យ៉ុនៈ បាទ!

បូលីៈ មកដីថៃនេះ! ហ៊ុណយ មកដីថៃនេះ ។

យ៉ុនៈ បាទ!

បូលីៈ ហ៊ុណយ បើយើងគិតទៅបុកដាំទេពួ?

យ៉ុនៈ មិនដឹងជាណាៗទេ ខ្ញុំមិនដឹងទេ ខ្ញុំមិនដែរទៅដែរហ៊ុណយ ។

បូលីៈ អត់ដឹងទេណ៎?

យ៉ុនៈ បាទ!

បូលីៈ ចឹងតាម៉ុក អស់ផ្លូវរត់ហើយចឹង?

យ៉ុនៈ បាទ!

បូលីៈ ចឹងពេលហ្នឹង ពួសួរថាប្រឹងចូលទៅចូលជាមួយអាមេរិចកាំងយ៉ាងម៉េចនោះ?

យ៉ុនៈ មិនដឹងដែរ ព្រោះខ្ញុំនៅតែក្រោមនេះ ។

បូលីៈ ដល់ដែរពេលណាបាន តាម៉ុក បរាជ័យ ហើយព្រមចុះចូលពួ?

យ៉ុងៈ ចូលជិតពាក់កណ្ដាល៩៩ហើយ ។

បូលីៈ ៩៩ហើយ?

យ៉ុងៈ បាទ!

បូលីៈ តាម៉ុក គេចាប់ខ្លួននៅខែ៣ ឆ្នាំ៩៩! ពេលដែលចាប់ខ្លួនហ្នឹង គាត់ចុះមកឲ្យចាប់ ឬក៏យ៉ាងម៉េចពូ? នរណាអ្នកចាប់តាម៉ុក កាលហ្នឹង?

យ៉ុងៈ ទេ! តាមខ្ញុំយល់ប្រហែលតាឌុន?

បូលីៈ តាឌុន?

យ៉ុងៈ បាទ! ព្រោះតាឌុន អ្នកយកគាត់ទៅលាក់ ទៅអី ។

បូលីៈ តាឌុន អ្នកលាក់តាម៉ុក?

យ៉ុងៈ បាទ!

បូលីៈ លាក់ម្ដុំណា?

យ៉ុងៈ ខ្ញុំមិនដឹងដែរ លាក់នៅថៃ ។

បូលីៈ ចឹងទាល់តែតាឌុន ហ្នឹងប្រាប់បានដឹងកន្លែងលាក់ បើចឹងម៉េចដឹងកន្លែងលាក់តាម៉ុក ។ ដូចជាមានសំនួរតែប៉ុណ្ណឹងទេ ពូបានផ្ដល់ព័ត៌មានខ្ញុំច្រើនមែនទែន ខ្ញុំបានដឹងច្រើន តាមរយៈពូណាពូ! អរគុណពូ ច្រើនណាស់ពូ បានជជែកលេងអស់១ម៉ោងជាង ។

យ៉ុងៈ បាទ!

«ចប់»